វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ការវិភាគខាងយេនឌ័រលើ
# កំណែទម្រង់វិមជ្ឈការនៅកម្ពុជា






គីម សេតានា និង Joakim Öjendal
រួមជាមួយ ឈួន ណារ៉េត និង លី គីម



ឯកសារពិភាក្សាលេខ ៧១

ខែ ធ្នូ ឆ្នាំ២០១៣

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

# ការវិភាគខាងយេនឌ័រលើ
# កំណែទម្រង់វិមជ្ឈការនៅកម្ពុជា

**ឯកសារពិភាក្សាលេខ ៧១**

**គឹម សេតាភ** និង **Joakim ÖJENDAL**
រួមជាមួយ **ឈួន ណារ៉េត** និង **លី តឹម**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
**ខែធ្នូ ឆ្នាំ២០១៣**

**បេសកកម្ម CDRI**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា។

© **រក្សាសិទ្ធិឆ្នាំ២០១៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ដែលអាចយកទៅចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី CDRI ឡើយ។

ISBN-13: 978-99950–52–67-6

**ការវិភាគខាងយេនឌ័រលើកំណែទម្រង់វិមជ្ឈការនៅកម្ពុជា**

( A Gendered Analysis of Decentralisation Reform in Cambodia)


| | |
|---|---|
| គឹម សេដារា | អតីតអ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) (kimsedara@fulbrightmail.org) |
| Joakim ÖJENDAL | ជាសាស្ត្រាចារ្យផ្នែកការសិក្សាសាកលនៃសាកលវិទ្យាល័យ Göteborg ប្រទេសស៊ុយអែត (joakim.ojendal@globalstudies.gu.se) |
| ឈួន ណារ៉េត | ជំនួយការកម្មវិធីក្នុងកម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) |
| លី តឹម | អតីតជំនួយការស្រាវជ្រាវក្នុងកម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ ហើយបច្ចុប្បន្នកំពុងសិក្សាបញ្ញាប័ត្រជាន់ខ្ពស់នៅប្រទេសញូហ្ស៊ីឡែន |


*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វបសអ/CDRI ទេ។*

**វិទ្យាស្ថាន CDRI**

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣

ទូរសារ៖ (៨៥៥ ២៣) ៨៨០ ៧៣៤; អ៊ីមែល៖ cdri@cdri.org.kh; http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ នន សុខចំរើន និង យូ សិទ្ធីរិទ្ធ

បកប្រែដោយ៖ ខេង សេង

បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ព ធី អេន អេស រាជធានីភ្នំពេញ

# មាតិកា


បញ្ជីរូបភាព និងតារាង ..... iv

បញ្ជីអក្សរកាត់ ..... v

សេចក្តីថ្លែងអំណរគុណ ..... vii

សម្រង់អត្ថបទ ..... ix

**១. សេចក្តីផ្តើម** ..... 1

១.១. គោលបំណង និងវិធីសាស្ត្រស្រាវជ្រាវ ..... 2

១.២. ដែនកំណត់ និងក្រមសីលធម៌ស្រាវជ្រាវ ..... 3

១.៣. ការទ្រទ្រង់ជាលក្ខណៈទ្រឹស្តី - "យេនឌ័រ" នៅក្នុងវិមជ្ឈការបែបប្រជាធិបតេយ្យ ..... 4

**២. សាវតារអភិបាលកិច្ចមានស្ត្រីចូលរួមនៅកម្ពុជាៈ ពេលមានការផ្លាស់ប្តូរនានា** ..... 6

២.១. និន្នាការចូលរួមក្នុងផ្នែកនយោបាយរបស់ស្ត្រី ..... 7

២.២. ស្ត្រី វប្បធម៌ និងការចូលរួមខាងនយោបាយ ..... 9

**៣. លទ្ធផលបានពីការពិនិត្យជាក់ស្តែង** ..... 11

៣.១. វិមជ្ឈការ និងផលប៉ះពាល់លើបញ្ហាយេនឌ័រ ..... 11

៣.២. បញ្ហាអ្នកតំណាងជាស្ត្រីក្នុងក្រុមប្រឹក្សាឃុំ ..... 13

៣.៣. បរិយាកាសសម្រាប់ឲ្យស្ត្រីបញ្ចេញមតិខាងនយោបាយ និងឥទ្ធិពលនៅក្នុងនយោបាយមូលដ្ឋាន ..... 17

**៤. ការពិភាក្សា និង សេចក្តីសន្និដ្ឋាន** ..... 24

៤.១. វិមជ្ឈការ និងភាពជាតំណាងផ្នែកនយោបាយមានលក្ខណៈយេនឌ័រនៅក្នុងក្រុមប្រឹក្សាឃុំ ..... 24

៤.២. លទ្ធភាពស្ត្រីក្នុងការបញ្ចេញមតិអំពីអាទិភាពផ្នែកនយោបាយ និងទស្សនៈផ្សេងៗ ..... 25

៤.៣. ការសន្និដ្ឋាន ..... 26

**ឯកសារយោង** ..... 28

**បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន** CDRI ..... 32

# បញ្ជីរូបភាព និងតារាង


រូបភាព ១៖ ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងឆ្នាំ ២០០២, ២០០៧ និង ២០១២ ....................................8

រូបភាព ២៖ អ្នកតំណាងផ្នែកនយោបាយជាស្ត្រី (ឆ្នាំ១៩៩៣-២០០៨) ............................................................9

រូបភាព ៣៖ រចនាសម្ព័ន្ធអំណាចនៅថ្នាក់ឃុំ/សង្កាត់.......................................................................................22

តារាង ១៖ ស្ត្រីក្នុងមុខងារអង្គនីតិបញ្ញត្តិ ឆ្នាំ១៩៩៣-២០១០.............................................................................7

តារាង ២៖ ស្ត្រីក្នុងមុខងារផ្នែកនីតិប្រតិបត្តិ នៅក្នុងអាណត្តិលើកទី ៤ (ឆ្នាំ២០០៨-២០១៣)................................8

តារាង ៣៖ មន្ត្រីស៊ីវិលជាស្ត្រី (ឆ្នាំ២០០៦-២០០៩) ........................................................................................8

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| CC | ក្រុមប្រឹក្សាឃុំ (Commune Council) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>(Cambodia Development Resource Institute) |
| CEDAW | អនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ<br>(Convention on the Elimination of all Forms of Discrimination against Women) |
| CNCW | ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី (Cambodian National Council for Women) |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា<br>(Committee for Free and Fair Elections) |
| CPP | គណបក្សប្រជាជនកម្ពុជា (Cambodian People’s Party) |
| D&D | វិសហមជ្ឈការ និងវិមជ្ឈការ (Deconcentration and Decentralisation) |
| DGPSR | កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ<br>(Democratic Governance and Public Sector Reform) |
| ICLD | មជ្ឈមណ្ឌលអន្តរជាតិសម្រាប់លទ្ធិប្រជាធិបតេយ្យក្នុងស្រុក<br>(International Centre for Local Democracy) |
| IULA | សហជីពអន្តរជាតិនៃអាជ្ញាធរមូលដ្ឋាន (International Union of Local Authorities) |
| LAMC | ច្បាប់ស្តីពីរដ្ឋបាល និងការគ្រប់គ្រងឃុំ/សង្កាត់<br>(Law on the Administration and Management of Communes/Sangkats) |
| MoWA | ក្រសួងកិច្ចការនារី (Ministry of Women’s Affairs) |
| NEC | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (National Election Committee) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-governmental Organisation) |
| PRK | សាធារណៈរដ្ឋប្រជាមានិត្យកម្ពុជា (People’s Republic of Kampuchea) |
| SSCS | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ (State Secretariat of Civil Service) |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (United Nations Development Programme) |

# សេចក្ដីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវនេះមិនអាចអនុវត្តបានទេ បើសិនពុំមានជំនួយគាំទ្រដ៏ប្រសើរពីបុគ្គល និងស្ថាប័នជាច្រើន។ ក្រុមអ្នកនិពន្ធសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយមូលនិធិដ៏សប្បុរសពី មជ្ឈមណ្ឌលអន្តរជាតិសម្រាប់លទ្ធិប្រជាធិបតេយ្យក្នុងស្រុក ( ICLD ) នៃប្រទេសស៊ុយអែត ដល់កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនិងកំណែទម្រង់វិស័យសាធារណៈ និងការគាំទ្រផ្នែកស្ថាប័នពីវិទ្យាស្ថាន CDRI ។

ក្រុមអ្នកនិពន្ធក៏សូមអរគុណចំពោះការចូលរួមចំណែក និងកិច្ចសហប្រតិបត្តិការដ៏មានតម្លៃរបស់អ្នកភូមិជាច្រើន សមាជិកក្រុមប្រឹក្សាឃុំ និងប្រធានភូមិ នៅតាមឃុំទាំងបួនដែលបានចុះសិក្សា។ ក្រុមអ្នកនិពន្ធសូមអរគុណដល់ លោកស្រី លី តឹម និងលោកស្រី ឈួន ណារ៉េត ចំពោះការចូលរួមចំណែកចុះប្រមូលទិន្នន័យ និងធ្វើកិច្ចការខាងស្រាវជ្រាវជាច្រើនទៀត និង លោកស្រី ធន់ វិមាលា លោក លន់ ពិដេ លោក អ៊ូ ស៊ីវហួច ចំពោះជំនួយគាំទ្រដ៏មានតម្លៃក្នុងលក្ខណៈជាសមាជិកក្រុមស្រាវជ្រាវ។

ក្រុមអ្នកនិពន្ធសូមអរគុណដល់បុគ្គលិក CDRI ជាច្រើនដែលបានផ្ដល់ការគាំទ្រខាងរដ្ឋបាលនិងភស្ដុភារ ក្នុងពេលធ្វើការស្រាវជ្រាវ ជាពិសេស លោក Larry Strange ជានាយកប្រតិបត្តិ និង លោក អ៊ឹង ស៊ានលី ជានាយកផ្នែកប្រតិបត្តិការ ដែលបានយកចិត្តទុកដាក់ជាខ្លាំង ជួយគាំទ្រដល់ការស្រាវជ្រាវនេះ។

# សម្រង់អត្ថបទ

ការបោះឆ្នោតឃុំ/សង្កាត់នៅឆ្នាំ២០០២ និង ២០០៧ ជាជំហានទៅមុខដ៏សំខាន់មួយក្នុងដំណើរការធ្វើវិមជ្ឈការបែបប្រជាធិបតេយ្យនៅកម្ពុជា។ វិមជ្ឈការជាកំណែទម្រង់វិស័យសាធារណៈដ៏ជ្រាលជ្រៅ និងជាការរីកលូតលាស់លទ្ធិប្រជាធិបតេយ្យដ៏សំខាន់បំផុតនៅកម្ពុជា។ កំណែទម្រង់បានកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធអំណាច បានបង្កើតបរិយាកាសសម្រាប់ឲ្យមានគណបក្សនយោបាយច្រើន និងបំផុសឲ្យមានការបញ្ចេញគំនិតថ្មីៗ។ មកទល់បច្ចុប្បន្ន កំណែទម្រង់នៅតែមានជួបបញ្ហាប្រឈមគួរឲ្យកត់សម្គាល់ សមាសភាពនារីមិនទាន់មានច្រើនគ្រប់គ្រាន់ក្នុងអង្គភាពធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយអាទិភាពផ្សេងៗ និងការបញ្ចេញគំនិតខាងយេនឌ័រទទួលបានការយកចិត្តទុកដាក់មានកម្រិត ហើយរចនាសម្ព័ន្ធអំណាចខាងយេនឌ័រនៅចាក់ឫសរឹងពិបាកផ្លាស់ប្តូរបាន។ ដោយផ្តោតលើវិមជ្ឈការបែបប្រជាធិបតេយ្យ និងសមភាពខាងយេនឌ័រ ការសិក្សានេះព្យាយាមពិនិត្យពីបរិយាកាសសម្រាប់ឲ្យស្ត្រីមានតួនាទីនៅក្នុងប្រព័ន្ធអភិបាលកិច្ចតាមមូលដ្ឋាន៖ តើតុល្យភាពយេនឌ័របានកើនឡើងប៉ុណ្ណា? តើស្ត្រីអាចបញ្ចេញនិងអនុវត្តគំនិតរបស់ខ្លួនបានយ៉ាងណានៅក្នុងមជ្ឈដ្ឋាននយោបាយតាមមូលដ្ឋាន? ដើម្បីឆ្លើយនឹងសំណួរទាំងនេះ ការសិក្សាបានផ្តោតលើបញ្ហាសំខាន់ពីរ៖ សមាសភាពស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ ការបញ្ចេញគំនិតខាងនយោបាយ និងឥទ្ធិពលស្ត្រីក្នុងមជ្ឈដ្ឋាននយោបាយនៅតាមមូលដ្ឋាន។

# ១
# សេចក្តីផ្តើម

ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ (LAMC) និង ច្បាប់ការបោះឆ្នោតឃុំ/សង្កាត់ ដែលបានប្រកាសនៅឆ្នាំ២០០១ បានកំណត់ពីវិមជ្ឈការបែបប្រជាធិបតេយ្យនៅកម្ពុជា។ ច្បាប់ទាំងពីរនេះ បានកំណត់យកឃុំ ជាស្ថានដ៏សំខាន់សម្រាប់អភិបាលកិច្ច និងការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។ តាំងពីពេលនោះមក ប្រទេសកម្ពុជា បានបោះឆ្នោតជ្រើសរើសឃុំ/សង្កាត់ នៅឆ្នាំ២០០២ និង ២០០៧ ដែលជាទូទៅគេចាត់ទុកជា កំណែទម្រង់វិស័យសាធារណៈដ៏ស៊ីជម្រៅ និង ជាការរីកចម្រើនលទ្ធិប្រជាធិបតេយ្យដ៏សំខាន់បំផុតនៅកម្ពុជា ចាប់តាំងពីការអនុវត្តរដ្ឋមនុញ្ញឆ្នាំ១៩៩៣ មក (Ojendal & Kim 2009)។ ដោយកសាងលើជោគជ័យពីដំបូងនៃកំណែទម្រង់រដ្ឋបាលមូលដ្ឋាននៅថ្នាក់ឃុំ/សង្កាត់នេះ នៅឆ្នាំ២០០៥ រដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវចក្ខុវិស័យរបស់ខ្លួន ដើម្បីធ្វើកំណែទម្រង់វិស័យសាធារណៈយ៉ាងទូលំទូលាយនៅក្រោមបដានៃ "វិសហមជ្ឈការ និងវិមជ្ឈការ" (D&D)។ កំណែទម្រង់នេះ ត្រូវបានរៀបចំឡើងជាក្បួនច្បាប់ឡើង តាមរយៈក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ។ តាមការអនុម័តច្បាប់រៀបចំអង្គការនៅខែកុម្ភៈ ២០០៨ និង ការបោះឆ្នោតដោយប្រយោលជ្រើសរើសក្រុមប្រឹក្សាស្រុក/ខណ្ឌ និងក្រុមប្រឹក្សាខេត្ត/រាជធានីនៅខែឧសភា ២០០៩ កម្ពុជាបានចាប់អនុវត្តដំណាក់កាលទី២នៃការធ្វើកំណែទម្រង់។ គេរំពឹងថា នឹងមានការផ្ទេរមុខងារ និងអំណាចដ៏សំខាន់ពីរដ្ឋអំណាចថ្នាក់កណ្តាល ទៅដល់ថ្នាក់ខេត្តនិងស្រុក ដើម្បីពង្រឹងការរីកលូតលាស់អភិបាលកិច្ចបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើកកម្ពស់ការផ្តល់សេវាកម្មមូលដ្ឋាននៅក្រោមប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឯកភាពមួយ និងបង្កើតកម្មវិធីអភិបាលកិច្ចគ្រប់ជ្រុងជ្រោយនៅថ្នាក់មូលដ្ឋាន តាមរយៈការប្រគល់មុខងារ។ សរុបមក ការធ្វើប្រជាធិបតេយ្យនីយកម្មដ៏ខ្លាំងក្លាបំផុតរបស់កម្ពុជា ក្រោយពេលមានអន្តរាគមន៍របស់អង្គកាសហប្រជាជាតិនៅឆ្នាំ១៩៩២/៣ នេះ បានរីងមាំរីកសាយដល់ថ្នាក់មូលដ្ឋាន និងកាន់តែសម្រាប់គ្រប់គ្នាឡើង។

កំណែទម្រង់នេះទាក់ទងទៅនឹងនយោបាយ ដែលជម្រុញដោយផលប្រយោជន៍ផ្សេងៗ ដូចជា តម្រូវការទទួលបានភាពពេញច្បាប់ខាងនយោបាយ ការការពារលំហូរសាច់ប្រាក់ និងការបង្កើតឋានៈក្នុងសង្គម (Hughes & Un 2007; Blunt & Turner 2005) ។ ដូចនេះ កំណែទម្រង់បានរៀបចំរចនាសម្ព័ន្ធអំណាចសាជាថ្មី បង្កើតបរិយាកាសឲ្យគណបក្សនយោបាយកាន់តែច្រើនឡើង បំផុសការបញ្ចេញមតិថ្មីៗ និងដោះស្រាយសមភាពយេនឌ័រក្នុងមជ្ឈដ្ឋាននយោបាយនៅតាមមូលដ្ឋាន ក៏ដូចជា គណនេយ្យភាព ការផ្តល់សេវាកម្ម និងការឆ្លើយតបជាទូទៅ (Kim 2012; Kim & Ojendal 2009)។ ដូច្នេះតាមទស្សនៈច្បាប់ កំណែទម្រង់ទាំងនេះ បង្កប់នូវសក្តានុពលអភិវឌ្ឍន៍ដ៏ខ្ពស់ (Manor 2008) ដូចជា ធ្វើឲ្យលទ្ធិប្រជាធិបតេយ្យកាន់តែស៊ីជម្រៅ សមភាពយេនឌ័រប្រសើរឡើង ការផ្តល់សេវាកម្មល្អជាងមុន និងជួយកែលំអហេដ្ឋារចនាសម្ព័ន្ធ។ ទោះជាយ៉ាងណាក្តី កំណែទម្រង់នេះបានជួបបញ្ហាប្រឈមជាច្រើន ដោយមានការរារាំងខ្លះដល់ការផ្លាស់ប្តូរ និងរចនាសម្ព័ន្ធសង្គមពីដើមនៅតែមានឥទ្ធិពលខ្លាំងជាង ក្នុងនេះ ទិដ្ឋភាពផ្សេងៗនៃការគិតគូរពីយេនឌ័រ ការចូលរួម និងលទ្ធិប្រជាធិយតេយ្យ ពិបាកបញ្ជ្រាបជាងគេ (Ojenal & Kim 2006; cf. Lilja 2010; cf. Kent 2010)។ ទោះបីមានសញ្ញានៃកំណើន សមភាពយេនឌ័រក្តី អ្នកតំណាងស្ត្រីក្នុងអង្គភាពធ្វើសេចក្តីសម្រេចចិត្តខាងគោលនយោបាយ នៅតែមិនទាន់គ្រប់គ្រាន់ ការបញ្ចេញមតិ និងអាទិភាពរបស់ស្ត្រីទទួលបានចម្លើយតបតិចតួច ហើយរចនាសម្ព័ន្ធអំណាច យេនឌ័រដែលមានស្រាប់នៅតែបន្តចាក់ឫសមាំមិនងាយផ្លាស់ប្តូរបានទេ។ Kent និង Chandler (2008: 128) បានលើកថា៖ បញ្ហាចែករំលែកអំណាចពិត និងការទទួលខុសត្រូវ នៅបន្តជាប់គាំងក្នុងទំនាក់ទំនងរវាងបែបបទចាស់និងថ្មី ដោយមានក្តីព្រួយបារម្ភជាខ្លាំងពីការបាត់បង់ប្រពៃណី និងការរលំរលាយក្រឹត្យក្រមសីលធម៌។ ដូច្នេះ ដំណើរការផ្លាស់ប្តូរបានចាប់ផ្តើមហើយ ប៉ុន្តែត្រូវជួបឧបសគ្គច្រើន។

លក្ខណៈផ្សេងៗនៃស្ថានភាពសង្គម-នយោបាយកំពុងផ្លាស់ប្តូរទៅមុខ ហើយភាពជាតំណាងក៏ត្រូវបានជម្រុញឡើងជាទូទៅដែរ។ នារីកម្ពុជាដែលចូលរួមក្នុងកិច្ចការនយោបាយបានរៀបចំ និងលើកកម្ពស់នយោបាយផ្តល់អត្តសញ្ញាណ ដោយបានកៀងគរ និងប្រកួតប្រជែងយកតំណែងក្នុងមុខងារសាធារណៈ (Lilja 2009) ប៉ុន្តែ ការចូល

រួមរបស់នារីក្នុងការសម្រេចចិត្ត នៅតែជួបឧបសគ្គ ហើយកិច្ចប្រឹងប្រែងបង្កើនឥទ្ធិពល សិទ្ធិបញ្ចេញមតិ និងចំនួនភាគរយនារីក្នុងមុខតំណែងនយោបាយ ជាតស៊ូដ៏លំបាកមួយ (COMFREL 2007a; Thon *et al.* 2009; cf. Öjendal & Kim 2006; cf. Lilja 2009)។ នៅកម្រិតបុគ្គល ទោះបីនារីកម្ពុជាសកម្មគួរសមក្តី ហើយជាក់ស្តែងបានគ្រប់ដណ្តប់លើការងារសេដ្ឋកិច្ចខ្នាតតូច និងការងារផ្ទះក្តី ក៏អ្នកផងនៅតែយល់ថា នារីចូលរួមក្នុងកិច្ចការនយោបាយវាមិនសមរម្យទេ (Ledgerwood 1992; Frieson 2001)។ ចំណុចនេះឆ្លុះបញ្ចាំងពីទស្សនៈអភិរក្សនិយមលើនយោបាយកម្ពុជា ប៉ុន្តែក៏មាននិន្នាការ និងឥទ្ធិពលថ្មីៗផុសឡើងច្បាស់ដែរ។ ដំណើរការកសាងឡើងវិញក្រោយចប់សង្គ្រាមបានចាប់ផ្តើមការផ្លាស់ប្តូរបែបបទចាស់ៗក្នុងសង្គម ដោយទទួលឥទ្ធិពលពីគោលការណ៍ប្រជាធិបតេយ្យបស្ចឹមប្រទេស សេដ្ឋកិច្ចទីផ្សារសេរី និងលំហូរចូលជំនួយអន្តរជាតិ (Ovesen *et al.* 1996; Öjendal & Kim 2006; Lilja 2010)។ ភស្តុតាងជាច្រើននៃសមភាពយេនឌ័រស៊ីជម្រៅ អាចពិនិត្យឃើញច្បាស់ ហើយដំណើរការក៏មានច្រើនផុសផុលដែលមិនធ្លាប់មានពីមុនមកទេ។ ត្រង់ចំណុចនេះ គួរយល់ស្របនឹងការអះអាងរបស់ Stiven (2010:1) ថា "ទំនើបកម្ម (នៅអាស៊ី) មានបង្កប់នូវដំណើរការលើកកម្ពស់យេនឌ័រ"។ ប្លែកពីការសិក្សាពីមុនៗរបស់ CDRI ស្តីពីកំណែទម្រង់ D&D នៅកម្ពុជា ការសិក្សានេះ ពិនិត្យលំអិតពីកម្រិតដែលកំណែទម្រង់ D&D បានជួយកែលំអបរិយាកាសឲ្យមានសមភាពយេនឌ័រក្នុងមជ្ឈដ្ឋាននយោបាយនៅតាមមូលដ្ឋាននៅកម្ពុជា។ ក្នុងកិច្ចប្រឹងប្រែងពិនិត្យពីបរិយាកាសសម្រាប់ឲ្យនារីបានចូលរួមក្នុងប្រព័ន្ធអភិបាលកិច្ចតាមមូលដ្ឋាននៅកម្ពុជានោះ ការសិក្សានេះព្យាយាមឆ្លើយនឹងសំណួរស្រាវជ្រាវដូចតទៅ៖ តើតុល្យភាពយេនឌ័របានប៉ុណ្ណាហើយ? តើនារីអាចបង្ហាញ និងអនុវត្តទស្សនៈរបស់ខ្លួននៅក្នុងមជ្ឈដ្ឋាននយោបាយតាមមូលដ្ឋានតាមរបៀបណា?

មុនពេលចូលដល់ការបង្កើតទ្រឹស្តី គួរបញ្ជាក់បន្ថែមពីរបៀបដែលត្រូវឆ្លើយនឹងសំណួរទាំងឡាយនៅខាងលើ។

## ១.១. គោលបំណង និងវិធីសាស្ត្រស្រាវជ្រាវ

តំណាងជាស្ត្រីដែលគិតជាតួលេខនៅក្នុងវេទិកានយោបាយ កំពុងមានការកើនឡើង (សូមមើលខាងក្រោម)។ ប៉ុន្តែយើងក៏ដឹងដែរថា នេះគ្រាន់តែជាដំណោះស្រាយតិចតួចមួយចំពោះបញ្ហាស្នូលដែលមិនមែនគ្រប់ដណ្តប់តែទៅលើភាពជាតំណាងឡើយ។ ស្របគ្នានឹងការស្រាវជ្រាវជាលក្ខណៈអន្តរជាតិនាពេលថ្មីៗនេះ ស្តីពីបញ្ហាយេនឌ័រក្នុងផ្នែកនយោបាយ (Kayumba 2010; Sylvester 1994; Rydström 2010) យើងគ្រាន់តែសម្តែងការចាប់អារម្មណ៍បន្តិចបន្តួចលើផ្នែកតួលេខប៉ុណ្ណោះ។ ការសិក្សាមានមូលដ្ឋានផ្អែកលើតួលេខនេះ អាចផ្តល់នូវលទ្ធផលមានសារៈប្រយោជន៍ក្នុងលក្ខណៈខុសប្លែកពីការស្រាវជ្រាវមុនៗក្នុងកម្រិតមួយ។ ដើម្បីឆ្ពោះទៅរកជោគជ័យផ្នែកគុណភាពយេនឌ័រនៅក្នុងកិច្ចការនយោបាយមូលដ្ឋានរបស់កម្ពុជា ចាំបាច់ត្រូវមានការពិនិត្យពិច័យពីដំណើរការស្រពេចស្រពិលដែលកើតចេញពីរចនាសម្ព័ន្ធអំណាចផ្អែកលើយេនឌ័រទាំងក្នុងលក្ខណៈជាក់លាក់ និងដោយប្រយោល។ ការវិភាគអំណាចយេនឌ័រពេញលេញមួយនៅក្នុងកិច្ចការនយោបាយមូលដ្ឋាន មានកម្រិតហួសពីដែនកំណត់នៃការសិក្សានេះ (cf. Lija 2009; cf. Frieson 201; Ledgerwood 1992) ប៉ុន្តែ យើងព្យាយាមបំពេញការវិភាគផ្នែកតួលេខ ឬ ភាពជាតំណាង និងការវិភាគពីការបញ្ចេញមតិរបស់ស្ត្រី ថាតើស្ត្រីកំពុងប្រើប្រាស់ភាពជាតំណាងរបស់ខ្លួនកាន់តែច្រើនជាងមុនឬ? និង តើសម្លេងរបស់ពួកគេត្រូវបានផ្សព្វផ្សាយ និងទទួលបានការអើពើឬទេ? ដូច្នេះ យើងសិក្សាអំពីកម្រិត២ ដែលនាំយើងទៅរកចរិតលក្ខណៈស្នូលនៃកិច្ចការនយោបាយនៅកម្ពុជា។

វិស័យសំខាន់ទាំងពីរនៃ ភាពជាតំណាង និង ការបញ្ចេញមតិនេះ នឹងត្រូវបានវិភាគក្នុងផ្នែកដាច់ៗពីគ្នា ហើយការបកស្រាយពីការវិភាគនោះ នឹងផ្តល់នូវការយល់ដឹងស៊ីជម្រៅថ្មីៗ សំខាន់ៗ ពីកំណែទម្រង់ D&D និងវិសាលភាពនៃកំណែទម្រង់ទាំងនោះក្នុងនាមជាយន្តការសម្រាប់ពង្រីកសមភាពយេនឌ័រ ជាពិសេស ក្នុងការធ្វើឲ្យតួនាទីយេនឌ័រមានលក្ខណៈជាផ្លូវការនៅក្នុងកិច្ចការនយោបាយ។ បញ្ហាសំខាន់ៗរួមមាន៖

• *តើការកំណត់យេនឌ័រនៃភាពជាតំណាងផ្នែកនយោបាយក្នុងក្រុមប្រឹក្សាឃុំ មានដំណើរការដូចម្តេច? គិតជាតួលេខ តើភាពជាតំណាងរបស់ស្ត្រី មានការវិវត្តដូចម្តេច ហើយមានន័យយ៉ាងណា?*

ក្នុងករណីដែលភាពជាតំណាងរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ មានការកើនឡើង៖

• *តើការបញ្ចេញមតិ និងចំណាប់អារម្មណ៍របស់ស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ ត្រូវបានអនុវត្តដូចម្តេច និងមានលទ្ធផលបែបណា? តើស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំ អាច ឬត្រូវបានអនុញ្ញាតឲ្យបញ្ចេញមតិផ្នែកនយោបាយ និងចំណាប់អារម្មណ៍របស់ពួកគេទាក់ទងនឹងមណ្ឌលបោះឆ្នោតយ៉ាងដូចម្តេច?*

វិស័យទាំងពីរខាងលើ ជាមូលដ្ឋាននៃអត្ថបទនេះ។ ការស្វែងយល់ពីបរិបទជាក់ស្តែង ទទួលបានជាចម្បងពីបទពិសោធន៍ស្រាវជ្រាវ និងការសិក្សាធ្លាប់មានពីមុនៗ របស់កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ (DGPSR) នៃវិទ្យាស្ថាន CDRI ចាប់តាំងពីឆ្នាំ២០០២មក (គិតបញ្ចូលទាំងការសិក្សារបស់ Thon *et al*. 2009; Öjendal & Kim 2006, 2011; Kim 2012)។ ឃុំដែលត្រូវបានជ្រើសរើសសម្រាប់ការស្រាវជ្រាវមាន ឃុំ TK ក្នុងខេត្តតាកែវ ឃុំ KC ក្នុងខេត្តក្រចេះ ឃុំ IT ក្នុងខេត្តបាត់ដំបង និង ឃុំ KL ក្នុងខេត្តកំពង់ចាម។[៧]

មូលហេតុសម្រាប់ការជ្រើសរើសឃុំទាំងបួននេះ គឺ៖

ក. ចំណេះដឹងមានច្រើនស្រាប់ទាក់ទងនឹងបរិបទជាក់ស្តែង បានពីការសិក្សាពីមុនៗនៅតំបន់ទាំងនេះ អាចឲ្យយើងស្វែងយល់ស៊ីជម្រៅទៅក្នុងស្ថានការណ៍ទូទៅ ផ្នែកនយោបាយ និង ផ្នែកសង្គម-សេដ្ឋកិច្ច។

ខ. ការសិក្សានេះ ផ្តោតលើឃុំដែលមានវត្តមានសំខាន់របស់នារី និងមានប្រធានក្រុមប្រឹក្សាជាប់ឆ្នោតជានារីដឹកនាំឃុំ។

គ. តំបន់សិក្សាមានតុល្យភាពផ្នែកភូមិសាស្ត្រ៖ ២ឃុំ (KC និង KL) នៅទិសខាងជើងឆៀងខាងកើតនៃប្រទេស ១ឃុំ (TK) នៅទិសខាងត្បូង និង ១ឃុំទៀត (TT) នៅទិសខាងជើងឆៀងខាងលិច។

ការសិក្សានេះប្រើទិន្នន័យបែបគុណភាព ទទួលបានពីការសម្ភាសស៊ីជម្រៅជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះរួមមាន៖ ប្រធានឃុំ (ជាស្ត្រីទាំងអស់) ក្រុមប្រឹក្សាឃុំ (មានបុរស និង ស្ត្រី) និង ប្រធានបក្សនយោបាយនៅក្នុងឃុំនីមួយៗ មេភូមិ (ភាគច្រើនជាបុរស) និង សមាជិកគណៈកម្មាធិការភូមិ (ភាគច្រើនជាស្ត្រី)។

ការស្រាវជ្រាវនេះ មិនមែនជាការសិក្សាប្រៀបធៀបពីក្រុមប្រឹក្សាឃុំទាំងបួនខាងលើទេ ប៉ុន្តែវាប្រើប្រាស់ការវិភាគកិច្ចការនយោបាយពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងក្រុមប្រឹក្សាឃុំ ដើម្បីយល់ដឹងស៊ីជម្រៅពីទិដ្ឋភាពឥទ្ធិពលយេនឌ័រទៅលើអំណាច នៅក្នុងដំណើរការកំណែទម្រង់ D&D ។ ដោយសារការសម្ភាស និងតំបន់សិក្សាមានកម្រិត ដូច្នេះការសិក្សានេះមិនតំណាងឲ្យរូបភាពពេញលេញនៃយេនឌ័រនៅក្នុងកិច្ចការនយោបាយមូលដ្ឋាននៅកម្ពុជាឡើយ ប៉ុន្តែវាគូសបញ្ជាក់ពីដំណើរការ និងបញ្ហាសំខាន់ខ្លះៗនៅក្នុងនោះ។ ចុងក្រោយបង្អស់ ដោយសារយើងជ្រើសរើសតែឃុំដែលមានស្ត្រីជាមេឃុំ ដូច្នេះសំណាកសម្រាប់ការសិក្សាមានភាពលំអៀងទៅរកឃុំដែលគាំទ្រស្ត្រី។ យ៉ាងណាក្តី សំណាកនេះ នឹងផ្តល់បទពិសោធន៍ និងចំណេះដឹងច្រើន។

## ១.២. ដែនកំណត់ និងក្រមសីលធម៌ស្រាវជ្រាវ

យើងយល់ដឹងពីក្រមសីលធម៌ និងទំនួលខុសត្រូវក្នុងការអនុវត្តតាមក្រមសីលធម៌ នៅពេលស្រាវជ្រាវអំពីអភិបាលកិច្ច។ តាមនិយមន័យ "យេនឌ័រ" ជាបញ្ហារសើបចាក់ស្រេះនៅក្នុងកិច្ចការនយោបាយ និងដែនឯកជន។ ទីមួយ វាបង្កើតជាភាពមន្ទិលចំពោះរចនាសម្ព័ន្ធអំណាចដែលមានស្រាប់ ធ្វើឲ្យអស្ថិរភាពរបៀបរបបទូទៅ និងរៀបចំរបៀបរបប

[៧] ឃុំទាំងនេះ មិនត្រូវបានបញ្ចេញឈ្មោះពិតឡើយ ដោយសារហេតុផលក្រមសីលធម៌ស្រាវជ្រាវ។

នោះជាថ្មីក្នុងចំណោមអ្នកមាន និងអ្នកក្រ។ ទីពីរ ការស្រាវជ្រាវពីយេនឌ័រ មានលក្ខណៈបុគ្គល ដោយសារវាធ្វើការកំណត់ និងចោទសួរពាល់អ្នកទទួលសម្ភាសន៍មិនថាបុរស ឬ នារី ស្តីពីលទ្ធភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ដូច្នេះ ការសម្ភាសចាំបាច់ត្រូវអនុវត្តដោយប្រុងប្រយ័ត្នទាក់ទងនឹងបញ្ហារសើប និងត្រូវមានវិធានការការពារអ្នកទទួលសម្ភាសន៍ពីផលវិបាកនានាដែលអាចកើតមានឡើងដោយសារសម្ភាសន៍នោះ។ ដើម្បីការពារការសម្ងាត់របស់អ្នកផ្តល់ព័ត៌មាន ការស្រាវជ្រាវនេះមិនបញ្ចេញនូវឈ្មោះរបស់ពួកគាត់ និងឈ្មោះពិតរបស់ឃុំ និងស្រុកដែលបានសិក្សាឡើយ។

## ១.៣. ការទទួលខ្ទង់ជាលក្ខណៈទ្រឹស្តី - "យេនឌ័រ" នៅក្នុងវិមជ្ឈការបែបប្រជាធិបតេយ្យ

វិមជ្ឈការ មិនមែនជាបាតុភូតថ្មីឡើយ គឺវាមានប្រវត្តិយូរឡុងមកហើយ (Rondinelli & Cheema 1983) និងបានក្លាយជានិន្នាការពិភពលោកមួយនៅក្នុងទសវត្សរ៍១៩៩០ ហើយត្រូវបានគេហៅថា "បដិវត្តន៍ស្ងប់ស្ងាត់" (Campbell 2003; cf. Grindle 2009; cf. World Bank 2008; cf. Öjendal 2002; cf. Manor 1999; cf. Crook & Manor 1998)។ មូលហេតុចំបងនៃការអនុវត្តវិមជ្ឈការដោយរដ្ឋាភិបាល ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍគឺដើម្បីពង្រីកលទ្ធិប្រជាធិបតេយ្យ និងការចូលរួមពីប្រជាជន នាំយករដ្ឋាភិបាលឲ្យចូលកៀកនឹងទីកន្លែងស្នាក់នៅ និងធ្វើការរបស់ប្រជាជន និងពង្រឹងទំនាក់ទំនងរវាងសង្គមស៊ីវិល និងរដ្ឋ (Litvack *et al.* 1998; Manor 1999)។ យ៉ាងណាក្តីវិមជ្ឈការជាវាក្យស័ព្ទដែលពិបាកនឹងបកស្រាយសម្រាប់ការអនុវត្តជាក់លាក់តាមប្រទេស។ការរចនានិងលទ្ធផលរបស់វាពឹងផ្អែកលើបរិបទសេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ គោលនយោបាយ និងសង្គម (Crook & Manor 1998; cf. Treisman 2006; cf. Manor 2011)។ ចំណុចនេះកាន់តែត្រូវជាពិសេស នៅពេលយើងផ្តោតលើទិដ្ឋភាពយេនឌ័រ (Ahikire 2007)។

ជាងដប់ឆ្នាំកន្លងទៅ *សេចក្តីប្រកាសជាលក្ខណៈសាកលរបស់* IULA *ស្តីពីនារីនៅក្នុងជួររដ្ឋាភិបាលមូលដ្ឋាន* បាន *លើកឡើងថា៖*

> រដ្ឋាភិបាលមូលដ្ឋាន ជាតំណែងវិសេសមួយ សម្រាប់រួមចំណែកក្នុងការព្យាយាមសម្រេចនូវសមភាពយេនឌ័រ ហើយអាចមានឥទ្ធិពលធំធេងលើឋានៈនារី និងស្ថានការណ៍សមភាពយេនឌ័រនៅជុំវិញពិភពលោក ដោយសារកម្រិតអភិបាលកិច្ចមានភាពជិតស្និទ្ធបំផុតនឹងប្រជាពលរដ្ឋ... *(ដកស្រង់ចេញពីអត្ថបទរបស់ Byrne & Schnyder 2005:6 នៅឆ្នាំ ១៩៩៨)*។

កំណែទម្រង់ស្ថាប័ន រំពឹងថានឹងបង្កើតលំហសម្រាប់ឲ្យនារីចូលរួម និងបញ្ចេញសិទ្ធិសេរីភាពរបស់ពួកគេ ហើយរដ្ឋាភិបាល ត្រូវតែធ្វើឲ្យសកម្មភាពទាំងនោះកើតឡើងយ៉ាងពេញលេញ (World Bank 2001)។ ការសិក្សាមួយដោយ Kazuki Iwanaga (2008) ស្តីពីភាពជាតំណាង និងការចូលរួមផ្នែកនយោបាយរបស់ស្ត្រីនៅតំបន់អាស៊ី សង្កេតឃើញថានារីទាំងអស់រួមគ្នាបង្កើតជាអំណាចសំឡេងឆ្នោតដ៏ធំធេង ប៉ុន្តែភាពជាតំណាងរបស់នារីក្នុងផ្នែកនយោបាយ មានការវិវត្តយឺតយ៉ាវនៅឡើយនៅក្នុងប្រទេសជាច្រើន។ ការទទួលបានសិទ្ធិស្មើភាពគ្នា គឺជាមូលដ្ឋាននៅក្នុងលទ្ធិប្រជាធិបតេយ្យ ហេតុនេះ នារីមានសិទ្ធិជាតំណាងដូចគ្នានឹងបុរសដែរនៅក្នុងឆាកនយោបាយ។ មានការអះអាងថា វិមជ្ឈការតាមបែបប្រជាធិបតេយ្យ មិនអាចសម្រេចបានឡើយ លុះណាតែនារីអាចចូលរួមទទួលអត្ថប្រយោជន៍នៅគ្រប់កម្រិតជាពិសេសនៅកម្រិតមូលដ្ឋាន (IULA 1998: 1)។

ចំណុចនេះ នាំឲ្យយើងចោទជាសំណួរថា តើនៅទីណា និងតាមវិធីណាដែលនារីអាចចូលរួមជាតំណាងបានពេញលេញ ឬ តើទីណា និងហេតុអ្វីបានជានារីមិនអាចចូលរួមជាតំណាងបានពេញលេញ? រដ្ឋាភិបាលមូលដ្ឋាន អាចជាចំណុចចាប់ផ្តើមងាយបំផុតសម្រាប់ការពង្រីកភាពជាអ្នកដឹកនាំរបស់នារី នៅក្នុងកិច្ចការនយោបាយ។ Byrne និង Schnyder លើកឡើងថា៖ "វិមជ្ឈការធ្វើឲ្យអភិបាលកិច្ចកម្រិតមូលដ្ឋានមានសារៈសំខាន់ឡើង ដោយដើរតួជាអ្នកផ្តល់សេវាកម្ម និងជាច្រកចូលទៅក្នុងប្រព័ន្ធនយោបាយ ហេតុនេះ វាជាវេទិកាគន្លឹះមួយសម្រាប់ការជំរុញអំណាចនយោបាយរបស់នារី" (2005:6)។ ពួកគាត់ បន្តទៀតថា៖

> រដ្ឋាភិបាលមូលដ្ឋាន អាចជាចំណុចសំខាន់សម្រាប់ឲ្យនារីចូលទៅក្នុងប្រព័ន្ធនយោបាយ... នារីប្រហែលងាយចូលរួមក្នុងផ្នែកនយោបាយនៅកម្រិតមូលដ្ឋាន ជាងនៅកម្រិតជាតិទៀត ដោយសារការជាប់រវល់ជាមួយការងារក្នុងផ្ទះ និងការងារគ្រួសារ និងការទ្រទ្រង់ពី NGOs នៅមូលដ្ឋាន និងក្រុមសហគមន៍នានា ដែលនាំឲ្យ កម្រិតមូលដ្ឋាន អាចជាចំណុចចាប់ផ្តើមងាយស្រួល សម្រាប់ការចូលរួមក្នុងសកម្មភាពនយោបាយ។ (2005:7)

ការសិក្សាមួយរបស់ UNDP បង្ហាញថា ការទ្រទ្រង់រដ្ឋាភិបាលមូលដ្ឋានតាមរយៈវិមជ្ឈការដែលជួយលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការអើពើនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ជាយន្តការសមស្របបំផុតសម្រាប់ការជម្រុញភាពជាតំណាងមានលក្ខណៈស្មើភាពផ្នែកយេនឌ័រ (UNDP 2000; World Bank 2001)។ លើសពីនេះទៀត Beall (2005) ពន្យល់ថា បទពិសោធន៍ពីប្រទេសអាហ្វ្រិចបង្ហាញថា វិមជ្ឈការតែងដើរតួជាយានសំខាន់មួយសម្រាប់បង្កើនការចូលរួមក្នុងកិច្ចការនយោបាយ និងភាពជាតំណាងរបស់នារី។

យ៉ាងណាក្តី យើងមិនអាចសន្និដ្ឋានជាទូទៅថា តំណាងរបស់នារីប្រកបដោយប្រសិទ្ធភាព នឹងផុសឡើងស្របគ្នាជាមួយវិមជ្ឈការឡើយ។ Ahikire (2007) លើកឡើងថា ទោះបីជាចំនួននារីចូលរួមក្នុងផ្នែកនយោបាយមានការកើនឡើង ប៉ុន្តែឥទ្ធិពលនៃការចូលរួមនោះមិនប្រាកដថាកើនឡើងដូចបរិមាណទេ។ គាត់បានរកឃើញថា នៅប្រទេសយូហ្គាន់ដា ការបញ្ចូលនារីទៅក្នុងឆាកនយោបាយ បានកើតមានឡើងក្នុងទំហំធំមួយ (សូម្បីដល់ថ្នាក់កំណត់កូតា) ប៉ុន្តែអំណាចរបស់នារីមិនបានជ្រាបទៅដល់មជ្ឈដ្ឋាននយោបាយតាមមូលដ្ឋានឡើយ។ ដូច្នេះ ការបង្កើតឡើងនៃរដ្ឋាភិបាលមូលដ្ឋានដែលមានការចូលរួម តាមរយៈវិមជ្ឈការតាមបែបប្រជាធិបតេយ្យ *អាចពង្រីកសមភាពនៃភាពជាតំណាងរបស់នារី ប៉ុន្តែលក្ខខណ្ឌផ្នែកសម្ភារៈ និងកិច្ចសន្ទនាក្នុងបរិយាកាសជុំវិញខ្លួនពួកគាត់ ក៏អាចជាឧបសគ្គចំពោះការបញ្ចេញសំឡេងស៊ីជម្រៅជាងមុនក្នុងផ្នែកនយោបាយផងដែរ។* បញ្ហានេះ ជាគំរូមួយដែលផុសចេញពីការសិក្សាធ្លាប់មានពីមុនមក។

ការពិភាក្សាខាងក្រោមនេះ ពិនិត្យលើបញ្ហាយេនឌ័រទូទៅនៅក្នុងបរិបទប្រទេសកម្ពុជា និងស្ថានការណ៍ផ្លាស់ប្តូរនៃតំណាងរបស់នារីនៅក្នុងស្ថាប័ននយោបាយមូលដ្ឋាន ព្រមទាំងស្វែងយល់ថាតើសំឡេងយេនឌ័រណាមួយដែលមានឥទ្ធិពលលើការអនុវត្តការងារ និងពិចារណាពីផលវិបាកនៃស្ថានការណ៍កំពុងប្តូរផ្លាស់នេះ។

## ២
# សាវតារអភិបាលកិច្ចមានស្ត្រីចូលរួមនៅកម្ពុជា៖ ពេលមានការផ្លាស់ប្តូរនានា

ផ្នែកនេះ បង្ហាញនូវបរិបទនៃភាពជាតំណាងរបស់ស្ត្រីក្នុងផ្នែកនយោបាយនៅកម្ពុជា ទាក់ទងនឹងក្របខ័ណ្ឌច្បាប់ ឯកសារគោលនយោបាយ និងការសិក្សាមុនៗលើប្រធានបទនេះ។ មានអត្ថបទមួយចំនួន បានលើកអំពីបញ្ហាយេនឌ័រ ក្នុងផ្នែកនយោបាយនៅកម្ពុជា[២] ប៉ុន្តែមិនទាន់មានការសិក្សាច្បាស់លាស់ទេថា តើកំណែទម្រង់វិមជ្ឈការបានលើកឬក៏បង្អាក់ទឹកចិត្តស្ត្រីយ៉ាងណាក្នុងការចូលរួមនៅក្នុងនយោបាយថ្នាក់មូលដ្ឋាន។ គេបានលើកថា តួនាទីយេនឌ័រនៅកម្ពុជាស្មុគស្មាញជាខ្លាំង ព្រោះគោលគំនិត "ទាន់សម័យ" វានៅលាយឡំជាមួយនឹង បែបបទបង្កប់ផ្សេងៗផ្នែកសង្គម ឥរិយាបថ ប្រពៃណី និងវប្បធម៌ ដែលតែងមានការប្រែប្រួល (Kent 2010)។ ចំណុចនេះបង្កើតបានជាបញ្ហាស្មុគស្មាញមិនដាច់ស្រេច។

ប្រអប់ ១៖ បញ្ហាយេនឌ័រមានឆ្លុះបញ្ចាំងក្នុងច្បាប់វិមជ្ឈការ

*មាត្រា ១៩ នៃអនុក្រឹត្យស្តីពី ការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ/សង្កាត់ (ឆ្នាំ២០០២៖ ៥-៨)៖*

ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវតែងតាំងសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ម្នាក់ជានារី ដើម្បីឲ្យទទួលបន្ទុកកិច្ចការនារី និងកុមារ។ ក្នុងករណីគ្មាននារីជាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវតែងតាំងនារីមួយរូបធ្វើជាជំនួយការទទួលបន្ទុកកិច្ចការនារី និងកុមារ។ សម្រាប់កម្រិតភូមិ មាត្រា ២២ នៃអនុក្រឹត្យនេះ ចែងថា ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវតែជាប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតនៃភូមិនោះ ហើយត្រូវមាននារីយ៉ាងតិចមួយរូប។ យោងតាមសភាពការណ៍ជាក់ស្តែងនៃភូមិនីមួយៗ ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវខិតខំជ្រើសរើសនារីឲ្យទទួលតំណែងជាមេភូមិ ឬអនុប្រធានភូមិ។

*យុទ្ធសាស្ត្រចតុកោណ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD 2010-2019: 85)៖*

ការលើកកម្ពស់សមភាព និងសមធម៌យេនឌ័រ ត្រូវបានទទួលស្គាល់ថាជាសមាសធាតុគន្លឹះនៃយុទ្ធសាស្ត្រនេះ។ ស្ត្រីត្រូវបានទទួលស្គាល់ថាជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ហើយយុទ្ធសាស្ត្រនេះកំណត់ថា ស្ត្រីទាំងអស់មានសិទ្ធិទទួលបានដោយស្មើភាពនូវសេវាថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលជំនាញ ការទទួលបានធនធាន និងចូលរួមសកម្មភាពសេដ្ឋកិច្ច និងតួនាទីធ្វើសេចក្តីសម្រេចនៅគ្រប់ថ្នាក់ និងគ្រប់វិស័យ។ សមភាពយេនឌ័រត្រូវបានទទួលស្គាល់ថា ជាធាតុដ៏ចាំបាច់មួយនៅក្នុងកម្មវិធីកំណែទម្រង់របស់រដ្ឋាភិបាល រួមមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងយុត្តិធម៌ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ នៅថ្នាក់ក្រោមជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ត្រូវធានាឲ្យមានតំណាងស្ត្រីនៅក្នុងក្រុមប្រឹក្សានៃរដ្ឋបាលទាំងនេះ។

[២] ការកត់សម្គាល់សំខាន់បំផុតគឺ Ebihar 1968, Ledgerwood (1990; 1992) UNDP 2000; Frieson 2001; Lilja (2009; 2010); Thon *et al*. 2009; Kent 2010; Derks 2010; Öjendal & Kim 2006; និង Kim & Öjendal (2011, 2012)។

ទី១ បញ្ហាយេនឌ័រ បានក្លាយជាផ្នែកដ៏សំខាន់មួយនៃគោលនយោបាយមេនៅកម្ពុជាក្នុងអំឡុងប្រាំឆ្នាំចុងក្រោយនេះ។ បញ្ហាយេនឌ័រដែលមានចែងក្នុងច្បាប់វិមជ្ឈការ (២០០១) មានសេចក្តីបញ្ជាក់បន្ថែម ទោះបីតាមបែបអភិវក្យបន្តិចក្តី នៅក្នុងមាត្រា១៩ នៃអនុក្រឹត្យឆ្នាំ២០០២ ស្តីពី ការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ/សង្កាត់ (សូមមើលប្រអប់ ១) និងមានចែងកាន់តែលំអិតនៅក្នុងយុទ្ធសាស្ត្រ D&D តាំងពីឆ្នាំ២០០៥ (RGC 2005) ហើយអាចមានលក្ខណៈច្បាស់លាស់បំផុតនៅក្នុងយុទ្ធសាស្ត្រចតុកោណនាពេលថ្មីៗនេះ (RGC 2010a)។ ការកែលំអដែលអាចកើតមានក្នុងលទ្ធភាពចូលរួមរបស់នារីក្នុងកិច្ចការនយោបាយ ពាក់ព័ន្ធនឹងការដឹកនាំនៅកម្រិតផ្សេងៗ គេឃើញថាបានកើតមានឡើងឆ្លងតាមកំណែទម្រង់រចនាសម្ព័ន្ធស្ថាប័ន ដូចជា D&D (ប្រអប់ ១) កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិធានការតម្រឹមនិងបន្សុីគ្នា និងយន្តការសម្រាប់បង្កើនប្រសិទ្ធភាព និងសមត្ថភាពឆ្លើយតបក្នុងបញ្ហាយេនឌ័រ (MoWA 2008)។ កំណែទម្រង់ស្ថាប័ននេះ ទោះបីមិនទាន់គ្រប់គ្រាន់ក្តី ក៏បានបញ្ឈប់នូវលំនាំពីមុនៗ និងបង្កើនការចូលរួមរបស់ស្ត្រីក្នុងមជ្ឈដ្ឋាននយោបាយ។

## ២.១. និន្នាការចូលរួមក្នុងផ្នែកនយោបាយរបស់ស្ត្រី

កំណើនតំណាងស្ត្រីក្នុងផ្នែកនយោបាយ សម្រេចបានជាចម្បង (និងរកឃើញច្រកចេញ) ឆ្លងតាមដំណើរការបោះឆ្នោតដោយផ្ទាល់ និងដោយប្រយោល ដែលស្តែងចេញតាមតួលេខមួយចំនួនដូចតទៅ៖ សមាមាត្រស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងរដ្ឋសភាជាតិ កើនឡើងគួរឲ្យកត់សម្គាល់ពី ៥% ក្នុងការបោះឆ្នោតជាតិនៅឆ្នាំ១៩៩៣ ដល់ ១២% នៅឆ្នាំ១៩៩៨ ១៩% នៅឆ្នាំ២០០៣ និង ២១% នៅឆ្នាំ២០០៨ (NIS 2008) (តារាង ១)។ ម៉្យាងទៀត សមាមាត្រស្ត្រីជារដ្ឋលេខាធិការ កើនពី ៧% នៅឆ្នាំ២០០៣ ដល់ ៧,៧% នៅឆ្នាំ២០០៨ រីឯសមាមាត្រស្ត្រីជាអនុរដ្ឋលេខាធិការ កើនពី ៩,៦% ដល់ ១៤,៦%។

ក្នុងកំណែទម្រង់ស្ថាប័នតាមរយៈច្បាប់រៀបចំអង្គការដែលបានចាប់អនុវត្តនាពេលថ្មីៗ ស្ត្រីមានចំណែក ១០,១% ក្នុងក្រុមប្រឹក្សាខេត្ត និងក្រុង និង ១២,៦% ក្នុងក្រុមប្រឹក្សាស្រុក ក្រុង និងខណ្ឌ (Lilja 2010)។ សមាមាត្រស្ត្រីជាប់ឆ្នោតក្នុងក្រុមប្រឹក្សាឃុំ កើនពី ៩,៤១% ក្នុងការបោះឆ្នោតឃុំ នៅឆ្នាំ២០០២ ដល់ ១៥,១២% នៅឆ្នាំ២០០៧ និង ១៨% នៅឆ្នាំ២០១២។ ក្នុងការជ្រើសតាំងព្រឹទ្ធសភាលើកដំបូងនៅឆ្នាំ១៩៩៩ ស្ត្រីទទួលបានអាសនៈ ១៤,៧៥%។ ប៉ុន្តែដោយមានការផ្លាស់ប្តូរទៅអនុវត្តការបោះឆ្នោតជាប្រយោលពីសំណាក់ក្រុមប្រឹក្សាឃុំក្នុងឆ្នាំ២០០៦ សមាមាត្រអាសនៈដែលស្ត្រីទទួលបាននៅក្នុងព្រឹទ្ធសភា នៅរក្សាតួលេខ ១៤,៧៥% ដដែល។[៣]

តារាង ១៖ ស្ត្រីក្នុងមុខងារអង្គនីតិបញ្ញត្តិ ឆ្នាំ១៩៩៣-២០១០

| ឆ្នាំ | ព្រឹទ្ធសភា (% នៃស្ត្រី) |
|---|---|
| 1999-2005 | 14.75 |
| 2006-2010 | 14.75 |
| **ឆ្នាំ** | **រដ្ឋសភាជាតិ (% នៃស្ត្រី)** |
| 1993 | 5.00 |
| 1998 | 12.00 |
| 2003 | 19.00 |
| 2008 | 21.00 |

ប្រភព៖ ទិន្នន័យរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (RGC 2010b: 26)

[៣] ពីដំបូង គណបក្សនយោបាយជ្រើសតាំងសមាជិកព្រឹទ្ធសភា ប៉ុន្តែចាប់ពីឆ្នាំ២០០២ មក ព្រឹទ្ធសភា ត្រូវបានបោះឆ្នោតជ្រើសតាំងដោយប្រយោលដោយក្រុមប្រឹក្សាឃុំដែលជាក្រុមនយោបាយមានលក្ខណៈអភិរក្សនិយមជាង (MoWA 2008)។

តារាង ២៖ ស្ត្រីក្នុងមុខងារផ្នែកនីតិប្រតិបត្តិ នៅក្នុងអាណត្តិលើកទី ៤ (ឆ្នាំ២០០៨-២០១៣)

| ឧបនាយករដ្ឋមន្ត្រី | | រដ្ឋមន្ត្រី | | រដ្ឋលេខាធិការ | | អនុរដ្ឋលេខាធិការ | |
|---|---|---|---|---|---|---|---|
| សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| 10 | 1 | 26 | 2 | 198 | 15 | 204 | 30 |
| 100% | 10% | 100% | 8% | 100% | 8% | 100% | 14.71% |

ប្រភព៖ ទិន្នន័យរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ - SSCS (RGC 2010b: 26)

រូបភាព ១៖ ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងឆ្នាំ ២០០២, ២០០៧ និង ២០១២




តារាង ៣៖ មន្ត្រីស៊ីវិលជាស្ត្រី (ឆ្នាំ២០០៦-២០០៩)

| 2006 | | 2007 | | 2008 | | 2009 | |
|---|---|---|---|---|---|---|---|
| សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| 167220 | 51046 | 176344 | 57114 | 179016 | 58270 | 182228 | 61298 |
| 100% | 31% | 100% | 32.38% | 100% | 32.55% | 100% | 34% |

ប្រភព៖ ទិន្នន័យ SSCS (RGC 2010b: 27)

រូបភាព ១ និង ២ ព្រមទាំង តារាង ២ និង ៣ បង្ហាញនូវចំណុចសំខាន់ពីរ។ ទី១ អ្នកតំណាងស្ត្រីក្នុងផ្នែកនីតិប្រតិបត្តិ និងផ្នែកនីតិបញ្ញត្តិ នៅមានចំនួនតិច នៅគ្រប់កម្រិត ហើយកន្លងមកមិនដែលមានពេលណា ដែលអ្នកតំណាងស្ត្រី បានកើនចំនួនឡើងជិតស្មើនឹងចំនួនអ្នកតំណាងបុរសនោះទេ។ អ្នកតំណាងស្ត្រី មានអត្រាខ្ពស់បំផុតត្រឹម ២០% ដូច្នេះនៅឃ្លាតឆ្ងាយជាខ្លាំងអំពីសមធម៌ខាងយេនឌ័រ។ ទី២ និន្នាការទាំងអស់កំពុងឈានទៅភ្ជិតគម្លាតដ៏ធំនេះ ហើយប្រសិនបើវាបន្តកើតមានសម្រាប់ការបោះឆ្នោតពីរបីលើកទៀតនោះ សមភាពយេនឌ័រក្នុងភាពអ្នកតំណាងផ្នែកនយោបាយ គួរតែអាចសម្រេចបាន។ តារាង ១-៣ បង្ហាញពី ភាគរយរបស់ស្ត្រីក្នុងជួររដ្ឋាភិបាលនៅកម្រិតរដ្ឋបាលខុសៗគ្នា។

រូបភាព ២៖ អ្នកតំណាងផ្នែកនយោបាយជាស្ត្រី (ឆ្នាំ១៩៩៣-២០០៨)




ប្រភព៖ NIS 2008

## ២.២. ស្ត្រី វប្បធម៌ និងការចូលរួមខាងនយោបាយ

បើពិនិត្យទៅក្នុងរង្វង់សង្គមវិញ ការសិក្សារបស់ May Ebihara ដែលធ្វើឡើងក្នុងទសវត្សរ៍១៩៦០ នៅសម័យមុនសង្គ្រាមស៊ីវិល អំពីតួនាទីរបស់ស្ត្រីក្នុងសង្គមជនបទកម្ពុជា (ជាការសិក្សាពេញលេញតែមួយគត់អំពីយេនឌ័រនៅកម្ពុជានៅមុនសង្គ្រាម) បង្ហាញថា អ្នកភូមិខ្មែរ មិនមានទំនៀមទំលាប់បែងចែកពលកម្មដោយសង្កត់ធ្ងន់ទៅលើភេទ និងអាកប្បកិរិយាផ្សេងៗ ដូចនៅក្នុងសង្គមជនបទមួយចំនួនទៀតនោះទេ។ កិច្ចការជាច្រើនគឺមានអនុវត្តដោយបុរស ឬនារី ឬភេទទាំងពីរតែម្តង ហើយជួនកាល បុរសធ្វើការងាររបស់ស្ត្រី ឬក៏ ស្ត្រីធ្វើកិច្ចការរបស់បុរស ដោយគ្មានការចំអក ឬការខ្មាសអៀនអ្វីទេ (Ebihara 1968: 190-191)។ នៅកម្ពុជាសម័យបច្ចុប្បន្ន ស្ត្រីមានតួនាទីជាច្រើនក្នុងសង្គម ហើយនៅក្នុងគ្រួសារស្ត្រីតែងមានសិទ្ធិគ្រប់គ្រងលើធនធាន និងមានទំនួលខុសត្រូវមើលថែទាំកូន។ នៅតំបន់ជនបទ ស្ត្រីតែងជួយការងារកសិកម្ម ហើយនៅទីក្រុង ស្ត្រីតែងធ្វើការក្នុងវិស័យក្រៅផ្លូវការ និងសហគ្រាស ជាពិសេសក្នុងរោងចក្រកាត់ដេរ ក៏ដូចជា ក្នុងទីផ្សារ និងក្នុងផ្នែករដ្ឋបាលសាធារណៈ (cf. Derks 2010)។

កាលពីដើម ការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ និងកិច្ចការនយោបាយ តែងផ្សារភ្ជាប់ខ្លាំងជាមួយនឹងចរិតលក្ខណៈជាបុរស ហើយការបង្ហាញកម្លាំងត្រង់ៗ បានក្លាយជាចំណុចសំខាន់បំផុត និងសម្រាប់គ្រប់ករណី ដើម្បីប្រមូលក្តោបក្តាប់អំណាចនយោបាយ (Ebihara 1968; Ledgerwood 1990; Ovesen *et al.* 1996; Luco 2002; Frieson 2001; Öjendal & Kim 2006; Lilja 2009)។ ដូច្នេះកន្លងមក ស្ត្រីបានរងការគាបសង្កត់ខាងនយោបាយ និង/ឬ ត្រូវគេបំបាត់សិទ្ធិអំណាច ប៉ុន្តែបញ្ហានេះ បាននិងកំពុងផ្លាស់ប្តូរសន្សឹមៗប៉ុន្មានឆ្នាំមកហើយ។ ជាឧទាហរណ៍ នៅទសវត្សរ៍១៩៨០ ស្របតាមប្រពៃណីក្នុងរបបកុម្មុយនីស្ត ចលនារបស់ស្ត្រី ត្រូវបានបង្កើតឡើងនៅក្នុងអង្គការរណសិរ្ស (ក្រុមស្នូលដែលរួមមាន សមាគមនារី និងសមាគមយុវជន)។ សកម្មភាពនេះ បាន (ឬគេសន្មតថាបាន) ជួយបង្កើនការអប់រំផ្នែកនយោបាយ ដើរតួជាស្ពានតភ្ជាប់រវាងបក្ស និងមហាជន ព្រមទាំងជាមូលដ្ឋានបណ្តុះបណ្តាលសម្រាប់សមាជិកបក្ស និងកម្មាភិបាលរដ្ឋនាពេលខាងមុខ (Gottesman 2003: 59)។ ស្ត្រីនៅតំបន់ជនបទ បានចូលរួមយ៉ាងច្រើនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តឡើងវិញនៅកម្ពុជាក្នុងទសវត្សរ៍១៩៨០។ ទោះយ៉ាងនេះក្តី មានស្ត្រីតិចនាក់ណាស់ដែលទទួលមុខតំណែងនយោបាយខ្ពស់ នៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (Iwannaga 2008)

ហើយប្រព័ន្ធកេណ្ឌប្រមូលនារី (ក្នុងលក្ខណៈក្រុមសង្គមមួយ) ដើម្បីបម្រើគណបក្សនយោបាយ នៅតែឃើញមានសេសសល់ខ្លះរហូតមកទល់សព្វថ្ងៃ។

ប្រទេសកម្ពុជាដែលទើបតែងើបពីសង្គ្រាមចាប់ពីឆ្នាំ១៩៩៣ មក បានទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីគោលការណ៍ប្រជាធិបតេយ្យ និងសេដ្ឋកិច្ចបែបទីផ្សាររបស់បស្ចឹមប្រទេស តាមរយៈលំហូរចូលនូវជំនួយ និងអន្តរាគមន៍អន្តរជាតិផ្សេងៗ ដែលមានលក្ខណៈផ្ទុយពីបែបបទជាប្រពៃណីនៅក្នុងទស្សនៈខ្មែរអំពីពិភពលោក និងយេនឌ័រ (Ovensen *et al.* 1996; Lilja 2009)។ តំណាងផ្នែកនយោបាយ ការធ្វើសេចក្ដីសម្រេចចិត្ត និងសមភាពយេនឌ័រ កំពុងត្រូវបានលើកកម្ពស់ដោយមានការគាំទ្រពីទីភ្នាក់ងារអន្តរជាតិនានា។ ម៉្យាងទៀត តួនាទីរបស់ស្ត្រីខាងផ្នែកនយោបាយ ក៏បានកើនឡើងដោយសារឥទ្ធិពលនៃសាកលភាវូបនីយកម្ម ក្នុងនោះមានទាំង ការណែនាំពីបែបបទថ្មីៗឆ្លងតាមរបៀបរបបនិងគោលនយោបាយរបស់អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារផ្ដល់ជំនួយ ជាពិសេសទាក់ទិននឹង អត្តសញ្ញាណខាងនយោបាយនៃតំបន់ជនបទនៅកម្ពុជា (Lilja 2009; 2010)។ ស្ថានភាពនេះបង្កើតបានជារូបភាពពីរគឺស្ត្រីត្រូវជាប់ផុងនៅក្នុងការរំពឹងទុកនិងបែបបទជាប្រពៃណីប៉ុន្តែត្រូវគេរំពឹងថានឹងទាមទារយកអាសនៈនៅក្នុងឆាកនយោបាយ ទោះបីមានការអញ្ជើញឲ្យចូលដោយទើសទាល់ក្ដី។ ប្រសិនបើស្ត្រីនៅតែរក្សាភាពអសកម្ម ពួកគេនឹងមិនទទួលបានអំណាចផ្នែកនយោបាយឡើយ ហើយប្រសិនបើពួកគេប្រឹងប្រែងទាមទារអំណាច នោះនឹងត្រូវគេចោទសួរតាមរយៈការរែកញែកបែបអភិរក្សនិយមដើម្បីការពារមុខដំណែងដែលមានស្រាប់។ កំណើនតំណាងស្ត្រីក្នុងជួរថ្នាក់ដឹកនាំនយោបាយ ផុសចេញជាសំខាន់ពីគោលគំនិតបែបអភិវឌ្ឍនិយម និងការផ្លាស់ប្ដូរជារួមឆ្ពោះទៅរកបរិយាកាសនយោបាយមួយដែលងាយបត់បែនមិនរឹងកំព្រឹសដូចមុន។ ក្នុងស្ថានភាពក្រោយបញ្ចប់ទំនាស់ ដែលការអភិវឌ្ឍវាក្លាយជាសំខាន់ជាងបញ្ហាសន្តិសុខ គឺអាចមានតម្រូវការ និងឱកាសកាន់តែច្រើនសម្រាប់ថ្នាក់ដឹកនាំជាស្ត្រី។

ការសិក្សាមួយក្នុងពេលថ្មីៗស្ដីពី ថ្នាក់ដឹកនាំនៅមូលដ្ឋាន បង្ហាញថា អ្នកដឹកនាំជាស្ត្រីប្រឈមនឹងឧបសគ្គចម្រុងៗផ្នែកវប្បធម៌ ប្រពៃណី សម្ពាធគ្រួសារ (តួនាទីបី) និងបញ្ហាពិបាកសម្គាល់ឃើញជាច្រើនទៀត (Thon *et al.* 2009)។ ជាទូទៅ ឧបសគ្គទាំងនេះ មានន័យថា អ្នកដឹកនាំជាស្ត្រីខ្វះការគាំទ្រ និងសហប្រតិបត្តិការពីសមាជិកគ្រួសារ និងអ្នករួមការងារ។ អ្នកដឹកនាំជាស្ត្រីមួយចំនួន បានប្រឈមនឹងការលះលែងប្ដី ដោយសារការចូលរួមក្នុងនយោបាយ។ ការសិក្សាបានរកឃើញដែរថា កង្វះភាពជឿជាក់លើខ្លួនឯង និងកង្វះសមត្ថភាពរបស់ស្ត្រីក្នុងការធ្វើជាអ្នកដឹកនាំថ្នាក់ខ្ពស់នៅមូលដ្ឋាន វាបណ្ដាលមកពីមូលហេតុពាក់ព័ន្ធផ្សេងៗ មិនមែនមកពីការយល់ឃើញថា ស្ត្រីមិនសក្ដិសមនឹងតំណែងនោះឡើយ។ ជាទូទៅ នេះជាការយល់ឃើញរបស់ថ្នាក់ដឹកនាំជាបុរស (និងស្ត្រីមួយចំនួន) និងអ្នកភូមិ ដែលបង្កើតបានជាទំនាយមួយនៅក្នុងគំនិតរបស់ពួកគេ។ បញ្ហានេះ ជាអន្ទាក់វិលវង់មួយ ព្រោះកង្វះទំនុកចិត្តលើសមត្ថភាពរបស់អ្នកដឹកនាំជាស្ត្រី ធ្វើឲ្យពួកគេមានអារម្មណ៍តូចទាបជាងគេ ដូច្នេះមន្ទិលសង្ស័យពីដំបូងនោះក៏ក្លាយជាការពិត (Thon *et al.* 2009)។

ស្ថិតិបង្ហាញថា អ្នកតំណាងស្ត្រីកាន់តែមានច្រើនឡើងនៅតាមកម្រិតផ្សេងៗក្នុងអង្គនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ឆ្លងតាមការបោះឆ្នោតដោយផ្ទាល់ និងដោយប្រយោល តាំងពីឆ្នាំ១៩៩៣ និង នៅថ្នាក់មូលដ្ឋាន តាំងពីឆ្នាំ២០០២។ តាមប្រវត្តិសាស្ត្រ ដំណាក់កាលដំបូងដែលមានតំណាងស្ត្រីនៅក្នុងវិស័យនយោបាយ បានចាប់ផ្ដើមក្នុងទសវត្សរ៍១៩៨០ ប៉ុន្តែទៅតាមបែបបទមួយដែលរាំងស្ទះលទ្ធភាពទទួលបានអំណាចពេញលេញ និងស្មើភាព។ ទោះបីមានការជំរុញបង្កើនសមភាពយេនឌ័រក្ដី ក៏ស្ត្រីនៅតែត្រូវប្រឈមនឹងឧបសគ្គជាច្រើន ដោយមិនមានការទទួលស្គាល់ពេញលេញឡើយនៅក្នុងការងារសង្គម នយោបាយ និងសេដ្ឋកិច្ចនៃសង្គមកម្ពុជា ដែលបង្កើតបានជាការលាយឡំគ្នាដ៏ស្មុគស្មាញនៃនយោបាយយេនឌ័រចាស់ នយោបាយយេនឌ័រថ្មី និងបែបបទខាងយេនឌ័រ។ ដើម្បីលាតត្រដាងពីភាពស្មុគស្មាញ ក្នុងដំណើរជឿនលឿនទៅមុខ និងប្រតិកម្មផ្សេងៗ នៃការកែលំអបរិយាកាសសម្រាប់ឲ្យស្ត្រីចូលរួមក្នុងអភិបាលកិច្ចនៅតាមមូលដ្ឋាននោះ ជំពូកបន្ទាប់នេះ មានបកស្រាយបង្ហាញពីការពិនិត្យអង្កេតជាក់ស្ដែងលើ ការចូលរួមផ្នែកនយោបាយ *តាមភាពជាតំណាង និងការបញ្ចេញមតិរបស់អ្នកដឹកនាំជាស្ត្រី* នៅក្នុងក្រុមប្រឹក្សាឃុំទាំងបួនដែលបានសិក្សា។

# ៣
# លទ្ធផលបានពីការពិនិត្យជាក់ស្តែង

> វិមជ្ឈការបានផ្លាស់ប្តូរក្រឹត្យក្រមចាស់ៗ និងរបៀបរបបអនុវត្តន៍របស់ស្ត្រី ហើយផ្តល់ឱកាសឲ្យស្ត្រីដូចជារូបខ្ញុំ បានចូលរួមក្នុងសកម្មភាពដឹកនាំនៅកម្រិតឃុំ តាមរយៈការបោះឆ្នោតថ្នាក់មូលដ្ឋាន។ ក្នុងឋានៈជាមេឃុំជាប់ឆ្នោត ខ្ញុំត្រូវដោះស្រាយបញ្ហាផ្សេងៗខាងសន្តិសុខ និងមានការទទួលខុសត្រូវជាទូទៅនៅក្នុងឃុំ។ ជួនកាល ការងារតម្រូវឲ្យខ្ញុំធ្វើដំណើរឃ្លាតឆ្ងាយពីផ្ទះទៅកាន់ខេត្តផ្សេងៗជាច្រើនថ្ងៃក្នុងមួយលើកៗ។ កាលពីដើម ការធ្វើដំណើរបែបនេះមិនអាចទទួលយកបានទេ ព្រោះគេយល់ថាមិនសមរម្យសម្រាប់ស្ត្រី ប៉ុន្តែបច្ចុប្បន្ន ខ្ញុំអាចធ្វើទៅបានដោយគ្មានការជំទាស់អ្វីពីសាច់ញាតិ ឬប្តីរបស់ខ្ញុំឡើយ។ នារីវ័យក្មេងជាច្រើនបានធ្វើដំណើរ និងធ្វើការឆ្ងាយពីផ្ទះ នៅតាមទីក្រុងជាយូរខែ ដើម្បីរកចិញ្ចឹមជីវិត។ ទង្វើនេះជួយឲ្យពួកគេមានទំនុកចិត្តលើខ្លួនឯងនិងមានភាពឯករាជ្យកាន់តែខ្ពស់។ *មេឃុំស្ត្រីនៅខេត្តបាត់ដំបង ថ្ងៃទី១២ កក្កដា ២០១០*

ទិន្នន័យប្រមូលបានជាក់ស្តែងដែលប្រើប្រាស់ក្នុងជំពូកនេះ បានមកពីប្រភពពីរផ្សេងគ្នា៖ ១) អង្កេតមូលដ្ឋានបែបបរិមាណក្នុងឆ្នាំ ២០០៨/០៩ លើអ្នកបោះឆ្នោតឆ្លើយសម្ភាសន៍ ៦៤៦នាក់ ក្នុង ៥ឃុំ នៅខេត្តកំពង់ស្ពឺ ក្រចេះ បាត់ដំបង កំពត និង សៀមរាប (Öjendal & Kim 2011) និង ២) ព័ត៌មានប្រមូលបាននៅឆ្នាំ២០១០ ក្នុងពេលធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយមេឃុំ (CC) សមាជិកក្រុមប្រឹក្សាឃុំ និងមន្ត្រីភូមិក្នុង ៤ឃុំ នៅខេត្តកំពង់ចាម ក្រចេះ តាកែវ និងបាត់ដំបង។ ជំពូកនេះចែកចេញជាបីផ្នែក ដោយវិភាគលើ៖ ១) តួនាទីទូទៅនិងផលប៉ះពាល់នៃវិមជ្ឈការលើយេនឌ័រ ទិន្នន័យអង្កេតបែបបរិមាណ និងទស្សនៈរបស់អ្នកផ្តល់ព័ត៌មានបុរស និងស្ត្រី ក្នុងឃុំ ២) តំណាងស្ត្រីក្នុងមជ្ឈដ្ឋាននយោបាយនៅមូលដ្ឋាន និង ៣) សមត្ថភាពស្ត្រីក្នុងការបញ្ចេញមតិ និងជះឥទ្ធិពលលើនយោបាយនៅមូលដ្ឋាន។

## ៣.១. វិមជ្ឈការ និងផលប៉ះពាល់លើបញ្ហាយេនឌ័រ

ដូចបានបង្ហាញពីមុន គេតែងសន្មតថា សម្រាប់ស្ត្រី ឆាកនយោបាយនៅមូលដ្ឋានងាយស្រួលនឹងចូលរួមជាង (UNDP 2002; Byrne & Schnyder 2005)។ តើជាទូទៅនៅកម្ពុជា វាយ៉ាងដូច្នេះដែរឬទេ?

បើមើលមួយភ្លែត ព័ត៌មានបានពីសម្ភាសន៍ និងការសង្កេតដល់កន្លែងបង្ហាញថា វិមជ្ឈការជាដំបូងនាំមកនូវឱកាសផ្សេងៗសម្រាប់ឲ្យស្ត្រីទទួលបានតួនាទីដឹកនាំក្នុងសហគមន៍។ ប៉ុន្តែវិធានការខ្លះមិនសូវស៊ីជម្រៅទេ ដូច្នេះត្រូវតែស្រាវជ្រាវវិភាគលំអិតតាមលក្ខណៈជាក់ស្តែងពីវិសាលភាពរបស់វា។ មេឃុំស្ត្រីម្នាក់នៅខេត្តតាកែវ បានបង្ហាញទស្សនៈផ្ទាល់ខ្លួនពីតួនាទីយេនឌ័រតាំងពីពេលអនុវត្តវិមជ្ឈការមកថា ៖ "(យើង)អាចនិយាយពីតួនាទីស្ត្រីក្នុងនយោបាយ និងការអភិវឌ្ឍនៅកម្រិតឃុំបាន ទោះបីពាក្យសំដីខ្លះគ្មានន័យអ្វីទេ ...." ។

គាត់បាននិយាយបន្តគួរឲ្យចាប់អារម្មណ៍ថា

> ....ប៉ុន្តែតាំងពីមានវិមជ្ឈការនៅឆ្នាំ២០០២ មក ស្ត្រីមួយចំនួនទទួលបានការយកចិត្តទុកដាក់ និងលើកកម្ពស់ពីគណបក្សនយោបាយរបស់ខ្លួន និងរដ្ឋាភិបាល ឲ្យបានចូលរួមដូចជាក្នុងការដឹកនាំនៅថ្នាក់មូលដ្ឋានជាដើម។ ដោយមានឱកាសទទួលបានការកសាងសមត្ថភាព និងបានយល់ដឹងពីសិទ្ធិរបស់ខ្លួន ស្ត្រីក៏ចាប់ផ្តើមទាមទារសិទ្ធិស្មើគ្នា និងបានចូលរួមយ៉ាងសកម្ម ក្នុងកិច្ចការសង្គមនៅក្នុងសហគមន៍....
> *មេឃុំស្ត្រី នៅខេត្តតាកែវ ថ្ងៃទី២៥ មិថុនា ២០១០*

ដូចជាច្បាស់លាស់ដែរដែល កំណែទម្រង់នាពេលថ្មីៗបានបំផុសជាបណ្ដើរៗនូវការយល់ដឹងពីយេនឌ័រ។ មេឃុំស្ត្រីម្នាក់នៅខេត្តបាត់ដំបងបានផ្ដល់ទស្សនៈពី វិមជ្ឈការ និងយេនឌ័រ ថា៖

> ការយល់ដឹងពីយេនឌ័រវាកាន់តែល្អប្រសើរឡើងហើយ ដោយសារកំណែទម្រង់វិមជ្ឈការ ដែលបានបើក (ឱកាស)ឲ្យស្ត្រីចូលរួមក្នុងការបោះឆ្នោត និងក្នុងសកម្មភាពសហគមន៍ជាច្រើន។ កំណើន(ចម្បង) នូវការយល់ដឹងពីយេនឌ័របានមកពីកិច្ចប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាល (NGO) និងប្រព័ន្ធផ្សព្វផ្សាយ។ *មេឃុំស្ត្រី នៅខេត្តបាត់ដំបង ថ្ងៃទី១២ កក្កដា ២០១០*

អ្នកផ្ដល់ព័ត៌មានជាច្រើននាក់និយាយថា ឧបសគ្គនៃក្រឹត្យក្រមប្រពៃណីលែងជាបញ្ហាចម្បងទៀតហើយ ដោយសារទស្សនៈរបស់បុរស និងស្ត្រីបានផ្លាស់ប្ដូរចាប់តាំងពីមានការអនុវត្តវិមជ្ឈការ។[៤] ទោះបីសំដីនេះអាចជាការសន្និដ្ឋានលឿនពេកក្ដី ក៏វាបង្ហាញពីតម្រូវការសង្កេតពិនិត្យថែមទៀតដែរ។ សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម បានលើកថា៖

> ឧបសគ្គនៃក្រឹត្យក្រមជាប្រពៃណីលើស្ត្រី មិនមែនជាបញ្ហាចម្បងទៀតទេ ព្រោះវាបានផ្លាស់ប្ដូរជាបណ្ដើរៗហើយ។ គ្រប់ស្ថាប័នហាក់ដូចបានធ្វើការខ្លាំងក្លា ដើម្បីផ្សព្វផ្សាយអំពីតម្លៃផ្សេងៗខាងយេនឌ័រ។ ប្រជាជនបានយល់ដឹងយ៉ាងច្បាស់ពីសិទ្ធិរបស់ខ្លួន រួមទាំងសមភាពស្ត្រីក្នុងគ្រប់វិស័យនៃសង្គម។ ស្ត្រីរងសម្ពាធតិចជាងពីក្រឹត្យក្រមជាប្រពៃណី បើធៀបទៅនឹងអតីតកាល។ *សមាជិកក្រុមប្រឹក្សាឃុំមួយក្រុម នៅខេត្តក្រចេះ ថ្ងៃទី១៦ មិថុនា ២០១០*

សមាជិកក្រុមប្រឹក្សាឃុំម្នាក់ទៀតនិយាយថា៖

> តាមទស្សនៈផ្ទាល់របស់ខ្ញុំ ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងសហគមន៍មានការផ្លាស់ប្ដូរ ដោយសារក្រឹត្យក្រមជាប្រពៃណីមិនមែនជាឧបសគ្គសម្រាប់ស្ត្រីទៀតឡើយ។ ជោគជ័យរបស់ស្ត្រីក្នុងស្ថានភាពជាអ្នកដឹកនាំ អាស្រ័យលើចរិតរបស់បុគ្គល ភាពក្លាហាន កម្រិតអប់រំ បណ្ដាញទំនាក់ទំនង និងការប្ដេជ្ញាចិត្ត។ ទោះយ៉ាងណាក្ដី អ្នកដឹកនាំស្ត្រីជាច្រើននៅតែត្រូវរ៉ាប់រងបន្ទុកច្រើនក្នុងគ្រួសារ ដូចជា មើលថែទាំកូន ធ្វើការងារផ្ទះ និងគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយរូប នៅខេត្តក្រចេះ ថ្ងៃទី១៧ មិថុនា ២០១០*

មានការទទួលស្គាល់ជាទូទៅថា អ្នកដឹកនាំជាស្ត្រីច្រើនតែសកម្ម និងមានការប្ដេជ្ញាខ្ពស់ក្នុងបញ្ហាសេដ្ឋកិច្ចគ្រួសារ និងកិច្ចការសង្គមកិច្ចក្នុងសហគមន៍ ជាងសហសេវិកជាបុរស។ សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម បានចែករំលែកទស្សនៈពីតួនាទីរបស់អ្នកដឹកនាំស្ត្រី ថា៖

> អ្នកដឹកនាំជាស្ត្រី តែងយកចិត្តទុកដាក់ខ្លាំងចំពោះសេដ្ឋកិច្ចគ្រួសារ ស្ត្រី កុមារ និងសុខុមាលសង្គមរបស់ប្រជាជនក្នុងសហគមន៍។ គាត់មិនរើសអើងចំពោះប្រជាជនមកពីបក្សនយោបាយផ្សេងទេ ព្រមទាំងមានតម្លាភាពល្អ និងមិនពុករលួយ។ នេះជាចរិតផ្ទាល់ខ្លួនដ៏ល្អរបស់គាត់។ គាត់តែងយកចិត្តទុកដាក់ចំពោះអ្នកក្រ និងអ្នកដទៃទៀតក្នុងឃុំ។ *សមាជិកក្រុមប្រឹក្សាឃុំមួយក្រុម នៅខេត្តកំពង់ចាម ថ្ងៃទី២៨ កក្កដា ២០១០*

[៤] ការផ្លាស់ប្ដូរក្នុងក្រឹត្យក្រមជាប្រពៃណី ក៏បង្កឡើងដោយសារកត្តាសេដ្ឋកិច្ច និងសង្គម និងចំណាកស្រុករបស់ប្រជាជនដែរ។

ទោះបីមានលទ្ធផលវិជ្ជមានជាច្រើនដែលផុសចេញជាសំខាន់ពីដំណើរការវិមជ្ឈការក្តី ក៏នៅតែមានមតិចម្រុះគ្នាអំពីការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងយេនឌ័រ។ សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុមនៅខេត្តតាកែវ បានផ្តល់យោបល់ថា៖

> ទោះបីជាមានការគាំទ្រខ្លាំង និងគោលនយោបាយពីរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍នានាដើម្បីលើកកម្ពស់ស្ត្រីក្តី ក៏ក្នុងកម្រិតណាមួយវានៅតែជាពាក្យពេចន៍នៅឡើយទេ ពីព្រោះក្នុងការអនុវត្តជាក់ស្តែងស្ត្រីនៅតែខ្វះទំនុកចិត្តលើខ្លួនឯង មានការអប់រំទាប និងត្រូវពឹងផ្អែកច្រើនលើបុរស។ គេលំបាកនឹងបញ្ចុះបញ្ចូលពួកគាត់ ឲ្យអនុវត្តសិទ្ធិរបស់ខ្លួនណាស់។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តតាកែវ ថ្ងៃទី២៤ មិថុនា ២០១០*

ឧបសគ្គមួយទៀតដែលរារាំងដល់ការកែលំអសមភាពយេនឌ័រ គឺកង្វះការប្តេជ្ញាចិត្តពេញលេញ ដើម្បីអនុវត្តគោលនយោបាយដែលបានព្រមព្រៀងហើយនៅគ្រប់កម្រិត។ មេឃុំស្ត្រីម្នាក់នៅខេត្តក្រចេះ បាននិយាយពីការសង្កេតឃើញរបស់គាត់ថា៖

> ការអនុវត្តជាក់ស្តែងក្នុងបញ្ហាយេនឌ័រ មិនស៊ីគ្នាជាមួយក្របខ័ណ្ឌច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលកណ្តាលទេ។ ក្នុងការគ្រប់គ្រងក្រុមប្រឹក្សាឃុំប្រចាំថ្ងៃ វាមានដំណើរការល្អ។ ប៉ុន្តែសព្វថ្ងៃនៅតែមិនទាន់មានតួនាទី ឬក៏ខ្សែរយៈប្រាស្រ័យទាក់ទងគ្នាច្បាស់លាស់ រវាងឃុំ គណបក្សនយោបាយ និងឥទ្ធិពលរបស់បុគ្គលទេ ហើយនៅតែមានជំហរមិនព្រមទទួលស្គាល់ស្ត្រីជាអ្នកដឹកនាំដោយពេញលេញ និងនៅតែគ្មានកិច្ចសហប្រតិបត្តិការយ៉ាងពេញលេញពីសំណាក់បុរសៗ។ *មេឃុំស្ត្រី នៅខេត្តក្រចេះ ថ្ងៃទី១៩ មិថុនា ២០១០*

ជារួម លទ្ធផលជាដំបូងៗនៃវិមជ្ឈការក្នុងការបង្កើនសមភាពយេនឌ័រមានលក្ខណៈគួរឲ្យពេញចិត្ត បើធៀបនឹងរយៈពេលដ៏ខ្លីដែលវាបានដំណើរការកន្លងមក។ ដូចបង្ហាញនៅខាងលើ អ្នកផ្តល់ព័ត៌មានជាច្រើននៅកម្រិតឃុំបានរាយការណ៍ពី ស្ថានភាពថ្មីមួយចំនួនដែលផុសឡើងនៅក្នុងមូលដ្ឋាន តាំងពីពេលចាប់អនុវត្តវិមជ្ឈការនៅឆ្នាំ២០០២មក។ ស្ថានភាពថ្មីទាំងនេះបង្កើតនូវបរិយាកាសសម្រាប់ឲ្យស្ត្រីបានចូលរួមក្នុងមជ្ឈដ្ឋាននយោបាយនៅមូលដ្ឋាន ដោយបង្កើនចំនួនអ្នកតំណាងជាស្ត្រី (អ្នកដឹកនាំ) នៅកម្រិតឃុំ និងភូមិ។ ម្យ៉ាងទៀត ស្ត្រីកាន់តែទទួលបានការពេញចិត្តពីសំណាក់គណបក្សនយោបាយរបស់ខ្លួន។ កំណែទម្រង់បានជះឥទ្ធិពលលើ និងជួយផ្លាស់ប្តូរក្រឹត្យក្រមចាស់/ប្រពៃណី ការយល់ឃើញពីតួនាទីរបស់ស្ត្រីក្នុងនយោបាយនៅមូលដ្ឋាន និងបានបង្កើនការយល់ដឹងជាសាធារណៈអំពីយេនឌ័រ ហើយស្ត្រីក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដាក់បញ្ហាសេដ្ឋកិច្ចគ្រួសារ និងបញ្ហាសង្គមកិច្ច ឲ្យចូលជាមួយគ្នានឹងការងាររបស់ក្រុមប្រឹក្សាឃុំ។ ការផ្លាស់ប្តូរជាបណ្តើរៗបានពិនិត្យឃើញច្បាស់គួរសមហើយ ថ្វីបើវាមិនទាន់មានន័យថា បានដោះស្រាយឧបសគ្គអស់នោះទេ ដូច្នេះគួរតែពិនិត្យលំអិតលើទិន្នន័យថែមទៀត។

## ៣.២. បញ្ហាអ្នកតំណាងជាស្ត្រីក្នុងក្រុមប្រឹក្សាឃុំ

ដូចបានឃើញខាងលើ តំណាងស្ត្រីនៅកម្រិតឃុំ និងភូមិ បានកើនឡើងជាបណ្តើរៗ។ ក្រៅពីស្ត្រីដែលជាប់ឆ្នោតជាមេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ ស្ត្រីមួយចំនួនបានស្ម័គ្រចិត្តបម្រើការជាជនបង្គោលក្នុងឃុំ ប្រធានភូមិ និងជំនួយការភូមិ។ អ្នកផ្តល់បទសម្ភាសន៍ជាច្រើននាក់បានអះអាងច្បាស់ថា អ្នកតំណាងជាស្ត្រីបានកើននៅគ្រប់កម្រិតនៃអាជ្ញាធរមូលដ្ឋាន ជាពិសេសនៅកម្រិតឃុំ និងភូមិ។ សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម បានបំភ្លឺថា៖

> ឃុំនេះ មានមេឃុំស្ត្រី និងស្មៀនស្ត្រី ហើយយើងមានទាំងអស់ ១៣ភូមិ។ នៅគ្រប់ភូមិ ស្ត្រីបានប្រឹងប្រែងធ្វើការដើម្បីជួយសហគមន៍។ ពួកគេមានការប្តេជ្ញាចិត្តខ្ពស់ណាស់ដើម្បីធ្វើការបម្រើអ្នកភូមិ ហើយនេះជា

ការរីកចម្រើនពិតៗក្នុងឃុំរបស់យើង....។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តកំពង់ចាម ថ្ងៃទី២៨ កក្កដា ២០១០*

ប្រជាជនជាច្រើនមានសុទិដ្ឋិនិយមថា អ្នកតំណាងស្ត្រីនឹងកើនឡើងទៀតនាពេលខាងមុខ។ សមាជិកក្រុមប្រឹក្សាឃុំបុរសមួយរូបបានផ្តល់មតិថា៖

នាបច្ចុប្បន្ន ស្ត្រីមានភាពក្លាហាន និងវៃឆ្លាតជាងពីមុន។ ខ្ញុំមានទំនុកចិត្តថា ចំនួនសមាជិកក្រុមប្រឹក្សាឃុំជាស្ត្រីនឹងកើនឡើង ដោយសារកំណើនការយល់ដឹងរបស់សាធារណជន ការតស៊ូមតិរបស់ស្ថាប័នជាច្រើន និងការប្តេជ្ញារបស់គណបក្សនយោបាយផ្សេងៗ ដើម្បីលើកទឹកចិត្តស្ត្រីឲ្យចូលរួមក្នុងការងារសង្គម។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយរូប នៅខេត្តក្រចេះ ថ្ងៃទី១៦ មិថុនា ២០១០*

ក្នុងប្រព័ន្ធបោះឆ្នោតបច្ចុប្បន្ន ស្ត្រីត្រូវតែធ្លាប់បានចូលរួមជាក់ស្តែង និងមានការប្តេជ្ញាចិត្តខ្ពស់ ពោលគឺ បានបម្រើគណបក្សនយោបាយយូរឆ្នាំ ទើបបក្សគិតគូរ និងដាក់ជាបេក្ខជនចម្បងក្នុងបញ្ជីបោះឆ្នោតរបស់បក្សដែលសំខាន់បំផុតដើម្បីឈានដល់ឋានៈខ្ពស់។ សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម មានយោបល់ថា៖

មូលហេតុដែលយើងមានមេឃុំស្ត្រីនៅឃុំនេះគឺ ដោយសារគាត់បានធ្វើការឲ្យគណបក្ស និងសហគមន៍ចាប់តាំងពីឆ្នាំ១៩៧៩ មក។ មូលហេតុមួយទៀតគឺ យើងបានធ្វើការបោះឆ្នោតថ្នាក់ឃុំចាប់តាំងពីឆ្នាំ២០០២ មក។ គាត់ក្លាយជាមេឃុំ ពីព្រោះសកម្មជនចាស់ៗមួយចំនួនបានស្លាប់ ប្តូរទីតាំង ឬលាឈប់។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តតាកែវ ថ្ងៃទី២៤ មិថុនា ២០១០*

ក្រៅពីការប្តូរផ្តាច់ចំពោះបក្សដែលជាលក្ខខណ្ឌដ៏សំខាន់បំផុតសម្រាប់ឲ្យស្ត្រី (ឬអ្នកណាទៀត) បានធ្វើជាអ្នកតំណាងក្នុងក្រុមប្រឹក្សាឃុំនោះ គេតែងយល់ឃើញជាទូទៅថា អ្នកដឹកនាំស្ត្រីច្រើនមានភាពអំណត់ ការយល់ចិត្ត ងាយជួបទាក់ទង សុភាពរាបសារ សប្បុរស និងមានចិត្តផ្សារភ្ជាប់យ៉ាងជ្រាលជ្រៅជាមួយសហគមន៍ ជាពិសេសជនក្រីក្រ គ្រួសារមានមេគ្រួសារទោលនិងកុមាររីឯបុរសមិនសូវមានគុណសម្បត្តិច្រើនដូច្នេះទេ។ជំទប់បុរសម្នាក់នៅខេត្តបាត់ដំបង និយាយថា៖

នៅឃុំនេះ អ្នកដឹកនាំស្ត្រីធ្វើការដោយអំណត់ និងយល់ដឹងពីស្ថានភាពមូលដ្ឋានបានល្អ ជាពិសេសបញ្ហាសុខុមាលភាពសង្គម។ មេឃុំស្ត្រីរបស់យើងកាន់តែមានការយល់ដឹង និងការពាក់ព័ន្ធច្រើនជាមួយប្រជាជន ហើយអ្នកណាក៏អាចជួបទាក់ទងគាត់បានដែរ។ គេគោរពគាត់ណាស់ក្នុងឃុំនេះ ពីព្រោះគាត់ទន់ភ្លន់ អំណត់ និងចិត្តល្អជាមួយគ្រប់គ្នាដោយគ្មានការរើសអើងលើបញ្ហានយោបាយ ឬមានក្រទេ។ ដើម្បីក្លាយជាអ្នកដឹកនាំល្អ មិនមែនសំខាន់ត្រឹមតែមានកម្រិតអប់រំ និងសមត្ថភាពនោះទេ ប៉ុន្តែត្រូវមានលក្ខណៈសម្បត្តិល្អៗទាំងនេះផង។ *ជំទប់បុរសម្នាក់ នៅខេត្តបាត់ដំបង ថ្ងៃទី១២ កក្កដា ២០១០*

មានការយល់ឃើញជាទូទៅដែរថា ស្ត្រីច្រើនមានសមត្ថភាពជាងបុរសក្នុងការគ្រប់គ្រងបញ្ហាសេដ្ឋកិច្ច និងសង្គមនៅក្នុងសហគមន៍ (ដូច្នេះ ក៏មានតម្រូវការ)។ សមាជិកបុរសម្នាក់ក្នុងក្រុមប្រឹក្សាឃុំ អះអាងថា៖

ចំពោះតួនាទីរបស់ស្ត្រីក្នុងអាជ្ញាធរឃុំ ស្ត្រីមានលទ្ធភាពកៀងគរស្ត្រីក្នុងសហគមន៍បានច្រើនជាង ដូចជានៅកម្រិតភូមិជាដើម។ ស្ត្រីពូកែរៃអង្គាស និងប្រមូលវិភាគទានក្នុងមូលដ្ឋាន និងពូកែស្វែងយល់ពីសេដ្ឋកិច្ចគ្រួសាររបស់អ្នកភូមិ ពីព្រោះគាត់និយាយភាសាដែលស្ត្រីឯទៀតក្នុងសហគមន៍ចង់ស្តាប់។ *សមាជិកក្រុមប្រឹក្សាឃុំបុរសម្នាក់ នៅខេត្តក្រចេះ ថ្ងៃទី១៦ មិថុនា ២០១០*

ស្រដៀងគ្នាដែរ សមាជិកស្ត្រីម្នាក់ក្នុងក្រុមប្រឹក្សាឃុំជាមួយគ្នា បញ្ចេញយោបល់ថា៖

ឆ្លងតាមវិមជ្ឈការ ឥឡូវនេះយើងមានមេឃុំជាស្ត្រី ហើយជាទូទៅក្នុងសង្គមយើង អ្នកផងតែងយល់ថា ស្ត្រីងាយជួបប្រាស្រ័យទាក់ទងជាង។ ចំពោះការដោះស្រាយ និងតស៊ូមតិក្នុងបញ្ហាសង្គម ដូចជាខាងសុខភាព អប់រំ និងដោះស្រាយទំនាស់ក្នុងសហគមន៍ ស្ត្រីមានប្រសិទ្ធភាពជាងបុរស។

ទោះបីចំណុចទាំងនេះអាចចាត់ទុកជាផ្នត់គំនិត និង/ឬ ការរៀបពាក្យសំដីឲ្យតែបានពិរោះក្តី ប៉ុន្តែជម្រៅនៃការដក់ជាប់ក្នុងចិត្ត (និងបានអនុវត្ត) ដោយបុរសនិងស្ត្រី នៅតែធ្វើឲ្យវាទៅជា "ពិតជាក់ស្តែង" បាន។ សមាជិកស្ត្រីដដែលបន្តទៀតថាៈ

សម្រាប់ទិដ្ឋភាពនយោបាយ គណបក្សមួយចំនួនដូចជា គណបក្សប្រជាជន ជាដើម មិនអាចជ្រោងខ្ពស់បង្កើនមេឃុំជាស្ត្រីបានទេ ដោយសារអាទិភាពផ្ទៃក្នុង និង/ឬ ឆន្ទៈនយោបាយរបស់បក្ស។ បេក្ខជនទី១ របស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ ត្រូវតែមានភាពវៃឆ្លាត ប្រជាប្រិយភាព និងការអប់រំ ហើយចំណុចសំខាន់បំផុតគឺ ត្រូវយល់ដឹងច្បាស់ពីបរិយាកាសក្នុងមូលដ្ឋាន និងអាចដោះស្រាយស្ថានភាពនៅមូលដ្ឋានបានល្អ។ ទោះយ៉ាងណាក្តី គ្រប់គណបក្សនយោបាយបានត្អូញត្អែរពី ការលំបាករកបានបេក្ខនារីមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ។ *សមាជិកក្រុមប្រឹក្សាឃុំស្ត្រីម្នាក់ នៅខេត្តក្រចេះ ថ្ងៃទី១៦ មិថុនា ២០១០*

ដូច្នេះ យន្តការឲ្យមានអ្នកតំណាងជាស្ត្រី អាស្រ័យជាសំខាន់លើកត្តាពីរៈ អាទិភាពរបស់គណបក្សនយោបាយ និងគុណសម្បត្តិរបស់បុគ្គល ហើយនិង ប្រវត្តិសាស្ត្រនិងឥរិយាបថ (និង តើអ្នកមូលដ្ឋានយល់ឃើញយ៉ាងណាដែរ)។[៥] ជនស្នូលស្ត្រីក្នុងភូមិម្នាក់ នៅខេត្តក្រចេះ បានបង្ហាញទស្សនៈថាៈ

(កម្រិតដែល)យើងមានស្ត្រីធ្វើការក្នុងឃុំ ឬភូមិ គឺកំណត់ឡើងដោយឆន្ទៈនយោបាយ និងថ្នាក់លើរបស់គណបក្សនីមួយៗ។ សម្រាប់ឃុំនេះ ប្រជាជនជាច្រើនមិនចូលចិត្ត CPP មិនមែនដោយសារគាត់មិនចូលចិត្តគណបក្សនេះទេ ប៉ុន្តែដោយសារមិនចូលចិត្តនឹងបេក្ខជនរបស់គណបក្ស។ ហេតុនេះហើយបានជាមេឃុំនៅឃុំនេះ គាត់មកពីគណបក្សផ្សេង និងជាស្ត្រី។ *ជនស្នូលជាស្ត្រីក្នុងភូមិ នៅខេត្តក្រចេះ ថ្ងៃទី១៦ មិថុនា ២០១០*

ដូចបង្ហាញនៅខាងលើ អ្នកតំណាងស្ត្រីកើនចំនួនជាបណ្តើរៗ ហើយប្រជាជនទទួលស្គាល់ថា ស្ត្រីអនុវត្តការងារបានល្អក្នុងតួនាទីជាអ្នកដឹកនាំផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងនយោបាយក្នុងសហគមន៍។ ប្រធានគណបក្សនយោបាយបុរសនៅកម្រិតឃុំម្នាក់និយាយថាៈ

មូលហេតុដែលគណបក្សប្រជាជនកម្ពុជាគ្មានមេឃុំជាស្ត្រី គឺមកពីបក្សមិនបានដាក់ស្ត្រីជាបេក្ខជនទី១ ក្នុងបញ្ជីរបស់គណបក្ស។ ដូចបានដឹងស្រាប់ហើយ ប្រព័ន្ធបោះឆ្នោតនៅកម្ពុជាឈរលើមូលដ្ឋានគណបក្ស។ បញ្ហាគ្មានមេឃុំស្ត្រីមានមូលហេតុបីៈ ទី១ ការលំបាករកបានបេក្ខនារីមានលក្ខណៈប្រកួតប្រជែង។ ទី២ មិនទាន់ដល់ពេលឲ្យស្ត្រីធ្វើជាមេឃុំ ព្រោះយើងត្រូវដោះស្រាយបញ្ហាសន្តិសុខដែលភាគច្រើនកើតឡើងនៅពេលយប់ ហើយខ្ញុំមិនទុកចិត្តថា ស្ត្រីហ៊ានចេញក្រៅនោះទេ។ ទី៣ វត្តមានស្ត្រី

---

៥ នេះជាបញ្ហាស្មុគស្មាញមួយ។ សព្វថ្ងៃនេះ អ្នកមានប្រវត្តិតស៊ូយូរឆ្នាំ និងប្តូរផ្តាច់ចំពោះបក្សជាច្រើននាក់ ត្រូវគេផាត់ចេញដោយសារបញ្ហាពុករលួយ និងបក្សពួកនិយមក្នុងជួរបក្ស ហើយវាបានអនុញ្ញាតឲ្យអ្នកចំណូលថ្មីដែលមានទំនាក់ទំនងល្អជាពិសេសមានប្រាក់ច្រើន បានឡើងឋានៈជាបន្តបន្ទាប់។ អ្នកចំណូលថ្មីទាំងនេះ ដែលជាទូទៅ គឺអ្នកមានប្រាក់សម្រាប់ចំណាយ ជាពិសេសលើការឃោសនាបោះឆ្នោត តែងទទួលបានការតម្លើងឋានៈលឿនរហូតដល់ជួរលើក្នុងបញ្ជីគណបក្ស ទោះបីមានប្រជាប្រិយភាពតិច និងការផ្សារខ្លួនកម្រិតទាបជាមួយសហគមន៍ក្តី។ លក្ខណៈនេះ អាចចាត់ទុកដំណាក់កាលទី១ ដែលប្រាក់កាសជ្រៀតចូលទៅក្នុងនយោបាយ គឺដូចគ្នានឹងប្រទេសកាន់លទ្ធិប្រជាធិបតេយ្យនៅអាស៊ីជាច្រើនទៀត ដូចជា ថៃ និង ហ្វីលីពីន ជាដើម (Seidl 2000; Arghiros 2001)។

ក្នុងមជ្ឈដ្ឋាននយោបាយនៅមូលដ្ឋានអាស្រ័យលើគណបក្ស ហើយក្នុងប្រព័ន្ធបច្ចុប្បន្នមិនសូវមានកន្លែងច្រើនសម្រាប់បេក្ខនារីទេ។ បក្សនៅមិនទាន់មានអាទិភាពខ្លាំងដើម្បីដាក់បេក្ខនារីនៅលំដាប់ទី១ ក្នុងបញ្ជីគណបក្ស។ នេះជាទស្សនៈផ្ទាល់របស់ខ្ញុំ ហើយវាមិនមែនដូចគ្នាសម្រាប់គ្រប់ក្រុមប្រឹក្សាឃុំនៅកម្ពុជាឡើយ ប៉ុន្តែនៅជនបទដាច់ស្រយាលដូចទីនេះ ស្ត្រីត្រូវជួបការលំបាក។ *ប្រធានគណបក្សនយោបាយមួយ នៅខេត្តក្រចេះ ថ្ងៃទី១៧ មិថុនា ២០១០*

អ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់ ក៏បានផ្សារភ្ជាប់ចំនួនអ្នកតំណាងស្ត្រី ទៅនឹងកម្រិត និងលក្ខណៈនៃការផ្ទេរអំណាចដែរ។ មេឃុំម្នាក់និយាយថា៖

អ្នកតំណាងស្ត្រីនៅកម្រិតឃុំ គ្រាន់តែជាពាក្យពេចន៍នៅឡើយ ...។ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាច្រើន អនុវត្តមិនទាន់បានល្អទេ។ អ្នកដឹកនាំភាគច្រើននៅកម្រិតឃុំ ធ្វើការដោយផ្អែកលើគោលនយោបាយរបស់គណបក្សខ្លួន ជាជាងលើគោលនយោបាយរដ្ឋាភិបាល។ ឧទាហរណ៍ ក្នុងឋានៈជាមេឃុំ ខ្ញុំដឹងច្បាស់ពីស្ថានភាព(ប្រជាជន)ក្នុងឃុំ ជាពិសេសអំពើហិង្សាក្នុងគ្រួសារ និងភាពក្រីក្រ ប៉ុន្តែខ្ញុំគ្មានធនធានសម្រាប់ជួយពួកគាត់ទេ។ *មេឃុំស្ត្រី នៅខេត្តក្រចេះ ថ្ងៃទី១៩ មិថុនា ២០១០*

ដូចបានបង្ហាញហើយ ការបង្កើនសមភាពយេនឌ័រនៅកម្រិតឃុំត្រូវជួបឧបសគ្គដោយសារ (ការយល់ថាមាន) កង្វះស្ត្រីដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងបរិបទតម្រូវឲ្យដោះស្រាយបញ្ហាពិបាកៗដូចជា ទំនាស់ដីធ្លី និងអំពើហិង្សាក្នុងគ្រួសារ។ សមាជិកក្រុមប្រឹក្សាឃុំមួយក្រុម បានវែកញែកលើបញ្ហានេះថា៖

នៅពេលយើងនិយាយពីតំណាងយេនឌ័រ យើងគួរផ្ដោតលើលទ្ធផលការងារជាក់ស្ដែង ហើយការបង្កើនចំនួនស្ត្រីក្នុងឃុំ គឺមិនគ្រប់គ្រាន់ទេ។ ឧទាហរណ៍ ក្នុងឃុំនៅតែមានបញ្ហាសង្គមជាច្រើន ដូចជា អំពើហិង្សាក្នុងគ្រួសារ និងជម្លោះដីធ្លីដែលមិនទាន់ដោះស្រាយ។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តកំពង់ចាម ថ្ងៃទី២៨ កក្កដា ២០១០*

សមាជិកក្រុមប្រឹក្សាឃុំភាគច្រើន បានចែករំលែកទស្សនៈរបស់ខ្លួនថា ការបានធ្វើជាអ្នកតំណាង វាមិនគ្រប់គ្រាន់ដើម្បីកែប្រែរចនាសម្ព័ន្ធអំណាចទេ។ បញ្ហាគុណភាព និងភាពទន់ខ្សោយ ដែលគេតែងចោទទៅលើអ្នកដឹកនាំជាស្ត្រីវាលែងងាប់ក្រឡាផ្លាស់ប្ដូរមិនបានទៀតហើយ។ ប្រធានក្រុមប្រឹក្សាឃុំស្ត្រីម្នាក់ នៅខេត្តតាកែវ បកស្រាយថា៖

នៅមានភាពមន្ទិលជាច្រើនអំពីសមត្ថភាពស្ត្រី ដូចជាការយល់ឃើញថា ស្ត្រីទន់ខ្សោយ មិនអាចធ្វើការបានល្អដូចបុរស មិនអាចដោះស្រាយបញ្ហាសន្តិសុខ និងកិច្ចការផ្សេងៗទៀតដែលគេចាត់ទុកជាការងាររបស់បុរស។ ការយល់ខុសទាំងអស់នេះ ត្រូវតែផ្លាស់ប្ដូរឲ្យបានដើម្បីលើកកម្ពស់តួនាទីស្ត្រីទៅថ្ងៃអនាគត។ *មេឃុំស្ត្រីម្នាក់ ខេត្តតាកែវ ថ្ងៃទី២៥ មិថុនា ២០១០*

បន្ទាប់ពីបានពិពណ៌នាពីលទ្ធផលរកឃើញជាក់ស្ដែងលើការយល់ឃើញនៅតាមមូលដ្ឋាន អំពីតំណាងជាស្ត្រីនៅកម្រិតឃុំមក ស្ថានភាពបច្ចុប្បន្នអាចសង្ខេបបាន ដូចតទៅនេះ៖

- តំណាងជាស្ត្រីនៅកម្រិតឃុំ និងភូមិ បានកើនឡើងតាមរយៈ ក្រុមប្រឹក្សាឃុំជាប់ឆ្នោត ជនស្ម័គ្រចិត្តក្នុងឃុំនិងភូមិ។ យើងបានរកឃើញនូវមតិយោបល់ជាទូទៅថា អ្នកដឹកនាំជាស្ត្រីមានការប្ដេជ្ញាចិត្តខ្ពស់ ហើយចូលរួមជួយ និងតំណាងឲ្យមណ្ឌលដែលគាត់ជាប់ឆ្នោតបានល្អ។

- ឥរិយាបថ និងការយល់ឃើញក្នុងចំណោមបុរស និងស្ត្រីក្នុងសហគមន៍ អំពីអ្នកតំណាងជាស្ត្រីនៅក្នុងមជ្ឈដ្ឋាននយោបាយ កំពុងមានការផ្លាស់ប្ដូរ ដោយពួកគេកាន់តែជឿជាក់លើអ្នកដឹកនាំជាស្ត្រី ទោះបីមានមតិប្រឆាំងខ្លះៗក៏ដោយ។ មូលហេតុចម្បងនៃការផ្លាស់ប្ដូរឥរិយាបថជាបន្តបន្ទាប់នេះគឺ ប្រជាជនជាច្រើនយល់ឃើញថា ស្ត្រីមានសមត្ថភាពដឹកនាំមូលដ្ឋានប្រកបដោយប្រសិទ្ធភាពដូច ឬខ្ពស់ជាងបុរស។

- វត្តមានតំណាងជាស្ត្រីក្នុងមជ្ឈដ្ឋាននយោបាយនៅមូលដ្ឋាន អាស្រ័យជាបឋមលើអាទិភាពរបស់គណបក្សនយោបាយ ដោយសារប្រព័ន្ធបោះឆ្នោតបានកំណត់យកវិធីចុះឈ្មោះក្នុងបញ្ជីគណបក្ស។ ប្រធានឃុំស្ត្រីតែងតែជួយប្រជាជនដោយមិនប្រកាន់និន្នាការនយោបាយឡើយ ហើយចំណុចនេះអាចផ្ទាក់លើគណបក្សមិនសូវពេញចិត្ត។
- ជួនកាលមានការអះអាងថា ស្ត្រីមានប្រសិទ្ធភាពជាងបុរសក្នុងការធ្វើទំនាក់ទំនងជាមួយប្រជាជនក្នុងសហគមន៍ ទាក់ទិននឹងបញ្ហាសេដ្ឋកិច្ច និងសង្គមរបស់ស្ត្រី។ តាមការយល់ឃើញជាទូទៅ ទំនាក់ទំនងដ៏រឹងមាំនេះកើតមានដោយសារអត្តចរិតធម្មជាតិរបស់ស្ត្រី ដែលជាប្រពៃណីតែងទន់ភ្លន់ ច្បាស់លាស់ អំណត់ និងសប្បុរស។
- ទោះបីភាពជាតំណាងរបស់ស្ត្រីបានរីកចម្រើនច្រើន នៅក្នុងគណបក្សនយោបាយតាមមូលដ្ឋានក្តី ក៏នៅមានឧបសគ្គពិបាកសម្គាល់ឃើញជាច្រើនទៀត ។ ឧទាហរណ៍ នៅមានភាពមិនស៊ីគ្នារវាង ក្របខ័ណ្ឌច្បាប់/គោលនយោបាយ នឹង ការអនុវត្តជាក់ស្តែង ហើយអ្នកដឹកនាំជាស្ត្រី មិនទទួលបានការគាំទ្រពេញលេញពីរដ្ឋាភិបាល គណបក្សនយោបាយ ឬអ្នករួមការងារជាបុរសទេ។ ទាំងអស់នេះបង្កើតបានជារបាំងក្រាស់ឃ្មឹកមួយ រារាំងសមភាពនៃភាពជាតំណាងក្នុងផ្នែកនយោបាយ។

សរុបមក តំណាងជាស្ត្រីបានកើនចំនួន និងមានការរីកចម្រើនលើការយល់ដឹងពីភាពជាតំណាងរបស់ស្ត្រីក្នុងឆាកនយោបាយ។ ដូច្នេះគួរបែរទៅពិនិត្យពីឥទ្ធិពល និងការបញ្ចេញមតិ និងសិក្សាថា តើភាពជាតំណាងកាន់តែស៊ីជម្រៅនេះមានឆ្លុះបញ្ចាំងយ៉ាងដូចម្តេចក្នុងកិច្ចការនយោបាយសកម្មប្រយុទ្ធ។

## ៣.៣. បរិយាកាសសម្រាប់ឲ្យស្ត្រីបញ្ចេញមតិខាងនយោបាយ និងឥទ្ធិពលនៅក្នុងនយោបាយមូលដ្ឋាន

ការបញ្ចេញមតិរបស់ស្ត្រីនៅទីនេះ មានន័យថា សមាជិកក្រុមប្រឹក្សាឃុំជាប់ឆ្នោតជាស្ត្រី មានស្វ័យភាព ចំណេះដឹង និងសមត្ថភាព (ដូចមានចែងក្នុងកំណែទម្រង់ D&D) ដើម្បីលើកឡើងឲ្យគេដឹងពីអាទិភាពនានារបស់គាត់នៅក្នុងកិច្ចពិភាក្សាវែកញែកផ្នែកនយោបាយជាផ្លូវការ និងក្រៅផ្លូវការ។ ចំណុចនេះទាក់ទងទៅនឹងសំណួររបស់ Spivak ថា តើអ្នកនៅក្រោមបង្គាប់ អាចនិយាយបាន និងមានគេស្តាប់ឮប៉ុណ្ណា (១៩៨៨)។ ដូច្នេះ យើងគួរយកចិត្តទុកដាក់ទី១ ពីលទ្ធភាពស្ត្រីក្នុងការនិយាយ និង ទី២ ពីកម្រិតដែលគេបានដឹងឮ ពោលគឺ ស្ត្រីអាចជះឥទ្ធិពល និងប្រើសិទ្ធិអំណាចបាន ។

សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម បានលើកពីទស្សនៈរបស់ខ្លួនលើបញ្ហានេះថា៖

> មេឃុំសព្វថ្ងៃនៅឃុំនេះ មានការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះប្រជាជន និងមានប្រជាប្រិយភាពខ្លាំង ព្រោះគាត់មិនប្រើអំណាចផ្ទាល់ខ្លួន ដើម្បីយកចំណេញលើអ្នកដទៃ។ គាត់យកចិត្តទុកដាក់ខ្លាំងចំពោះបញ្ហាសុខុមាលភាពស្ត្រី កុមារ និងសង្គម។ គាត់មិនរើសអើងប្រជាជនមកពីបក្សនយោបាយផ្សេងៗ មានតម្លាភាពល្អនិងមិនពុករលួយ។គណបក្សនយោបាយរបស់គាត់ជឿជាក់លើរូបគាត់ព្រោះគាត់បានធ្វើការឲ្យអាជ្ញាធរមូលដ្ឋានតាំងពីឆ្នាំ១៩៧៩ មក។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តកំពង់ចាម ថ្ងៃទី២៨ កក្កដា ២០១០*

សំដីដកស្រង់ខាងលើ បង្ហាញពីទិដ្ឋភាពសំខាន់ៗមួយចំនួនដែលអាចជួយក្រុមប្រឹក្សាឃុំជាស្ត្រីក្នុងការបញ្ចេញមតិលើការទទួលខុសត្រូវរបស់ខ្លួន មានជាអាទិ៍ ប្រជាប្រិយភាពក្នុងចំណោមប្រជាជនមូលដ្ឋាន ការធ្វើការងារដោយមានតម្លាភាព និងការប្តេជ្ញាចិត្តបម្រើសហគមន៍។ ដោយមានចរិតលក្ខណៈទាំងអស់ខាងលើនេះ ថ្នាក់ដឹកនាំជាស្ត្រីអាចទទួលបានការពេញចិត្តពីគណបក្សគាត់ ព្រោះបក្សនឹងទទួលបានការគាំទ្រនៅពេលបោះឆ្នោត។ នេះជាហេតុផល

*ចម្បងបំផុត* នៃការពង្រឹងរបបប្រជាធិបតេយ្យនៅមូលដ្ឋានឲ្យមានតុល្យភាពផ្នែកយេនឌ័រ ព្រមទាំង តួនាទីកាន់តែច្រើនសម្រាប់ស្ត្រី និង*សម្រាប់* គណបក្សនយោបាយ។

ដូច្នេះ សមត្ថភាព *ជាក់ស្តែង* របស់ស្ត្រី ដើម្បីបញ្ចេញមតិប្រកបដោយប្រសិទ្ធភាពលើការទទួលខុសត្រូវរបស់ខ្លួន កើតមានតាមរយៈ ទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការទទួលបានពីមជ្ឈដ្ឋានផ្សេងៗកំពុងគ្របដណ្តប់ដោយបុរស (នគរបាល អាជ្ញាធរស្រុក/ឃុំ និងអ្នកមានឥទ្ធិពលសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន) ដែលរួមដៃគ្នា(អាចដោយអចេតនា) គ្របដណ្តប់/ត្រួតត្រាលើការជជែកវែកញែកផ្នែកនយោបាយ។ ការគ្របដណ្តប់នេះ អាចពិនិត្យឃើញនៅកន្លែងជាច្រើន (Ahikire 2007)។ ជំទប់បុរសមួយរូបនៅខេត្តបាត់ដំបង បានប្រមើលមើលថា៖

> វាគ្មានខុសគ្នាអ្វីទេរវាងសមត្ថភាពបុរស និងស្ត្រី (ក្នុងការបញ្ចេញមតិពីអាទិភាព) ក្នុងការអនុវត្តកិច្ចការរបស់ខ្លួន។ នៅអំឡុងពេលប្រយុទ្ធជាមួយពួកខ្មែរក្រហម មានស្ត្រីជាច្រើនបានចូលក្នុងកងទ័ព។ ស្ត្រីអាចធ្វើការងារបានល្អដូចបុរសដែរ។ *ជំទប់បុរស នៅខេត្តបាត់ដំបង ថ្ងៃទី១២ កក្កដា ២០១០*

កត្តាសំខាន់មួយទៀត កើតចេញពីវត្តមានធនធានហិរញ្ញវត្ថុ។ កង្វះធនធានហិរញ្ញវត្ថុ ធ្វើឲ្យការបញ្ចេញមតិពីអាទិភាពផ្សេងៗរបស់អ្នកដឹកនាំជាស្ត្រី វាគ្រាន់តែជា "សំនួនវោហា" (ដូចបានឃើញខាងលើ) ព្រោះត្រូវពឹងផ្អែកដដែលលើការទ្រទ្រង់ផ្នែកសម្ភារៈ និងហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ និងរដ្ឋាភិបាលកណ្តាលតាមរយៈមូលនិធិឃុំ/សង្កាត់។[៦] សមាជិកក្រុមប្រឹក្សាឃុំមួយក្រុម នៅខេត្តតាកែវ បានបញ្ចេញទស្សនៈថា៖

> វិមជ្ឈការ ពិតជាល្អសម្រាប់ស្ត្រី ព្រោះពួកគេអាចចូលទៅក្នុងប្រព័ន្ធនយោបាយថ្នាក់ឃុំ ប៉ុន្តែ (ការចូលរួមសកម្មរបស់ពួកគេ) បើពិនិត្យតាមសមត្ថភាពធ្វើការងារផ្សេងៗ គឺមិនទាន់បានទូលំទូលាយដូចអាជ្ញាធរឃុំចង់បាននោះទេ។ កង្វះធនធានជាបញ្ហាចម្បង ដែលរារាំងដល់សមត្ថភាពស្ត្រីក្នុងការឆ្លើយតប (ចំពោះមតិ និងសំណើផ្សេងៗ)[៧] និងការសម្រេចចិត្តដោយឯករាជ្យ។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តតាកែវ ថ្ងៃទី២៤ មិថុនា ២០១០*

ទោះយ៉ាងណាក្តី ក្រុមប្រឹក្សាឃុំជាទូទៅមិនអាចបំពេញគ្រប់តម្រូវការរបស់ប្រជាជននោះទេ។ ដើម្បីធ្វើឲ្យប្រជាជនយល់ដឹងពីការលំបាកដែលរារាំងក្រុមប្រឹក្សាឃុំ មិនឲ្យមានលទ្ធភាពឆ្លើយតបបានពេញលេញនោះ មេឃុំក៏ដូចជាក្រុមប្រឹក្សាឃុំទាំងអស់ ត្រូវមានលក្ខណៈទន់ភ្លន់អាចបត់បែនបាន អត់ធ្មត់ និងមានតម្លាភាពក្នុងការចាត់ចែងការងារជាមួយប្រជាជន។ មេឃុំស្ត្រីមួយរូបនៅខេត្តបាត់ដំបង បានពន្យល់ថា៖

> ជានិច្ចជាកាល ប្រជាជនមានសំណើជាច្រើនដល់ឃុំ ហើយពួកយើងមិនអាចបំពេញតាមរាល់តម្រូវការរបស់ពួកគេទេ។ វិធីសាស្ត្រល្អបំផុតដើម្បីដោះស្រាយបញ្ហា គឺពន្យល់ (ពីស្ថានភាព) ឲ្យច្បាស់ដល់ពួកគាត់ និងប្រាប់ពីចំនួនថវិកាពិតប្រាកដដែលក្រុមប្រឹក្សាឃុំទទួលបានជារៀងរាល់ឆ្នាំ។ *មេឃុំស្ត្រី នៅខេត្តបាត់ដំបង ថ្ងៃទី១២ កក្កដា ២០១០*

ស្រដៀងគ្នាដែរ មេឃុំម្នាក់នៅខេត្តបាត់ដំបង និយាយថា៖

---

៦ ការពឹងផ្អែកលើរដ្ឋាភិបាលកណ្តាល និងគណបក្សនយោបាយ/អ្នកមានឋានៈខ្ពស់ ជាកត្តាចម្បងដែលរារាំងអ្នកដឹកនាំស្ត្រីក្នុងការបញ្ចេញមតិពីតួនាទីរបស់ខ្លួន និងធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព។ ការគាំទ្រច្រើនៗដែលគាត់តែងទទួលបាននៅក្នុងមូលដ្ឋាន វាមិនសុទ្ធតែអាចធ្វើឲ្យស្ថានភាពសព្វថ្ងៃនេះប្រែប្រួលទេ។ ដរាបណាអាជ្ញាធរវិមជ្ឈការនៅតែពឹងផ្អែកលើមូលនិធិពីមជ្ឈឹមនោះ ប្រជាប្រិយភាព និងភាពពេញច្បាប់នៅថ្នាក់មូលដ្ឋាន នៅតែមិនអាចបង្កើនលទ្ធភាពប្រមូលចំណូល ហើយវាជះឥទ្ធិពលតិចតួចណាស់ទៅលើអ្វីដែលអាចសម្រេចបាន (ព្រោះឧបសគ្គខាងហិរញ្ញវត្ថុ ជាការរាំងស្ទះចម្បងដល់ការរីកចម្រើនក្នុងរយៈពេលខ្លី)។

៧ ពាក្យ ការបញ្ចេញមតិ (ឆ្លើយតប) មានន័យថា សមត្ថភាពបំពេញការងារដោយឯករាជ្យប្រកបដោយភាពទទួលខុសត្រូវ។

តាមការយល់ឃើញរបស់ខ្ញុំផ្ទាល់ សមាជិកក្រុមប្រឹក្សាឃុំ ជាពិសេសស្ត្រីដូចរូបខ្ញុំ មានឱកាសច្រើនជាងមុនដើម្បីចូលរួមក្នុងការដឹកនាំឃុំ។ ទោះយ៉ាងនេះក្តី ឧបសគ្គចម្បងចំពោះការអនុវត្តទំនួលខុសត្រូវនានា គឺយើងមិនមានចំណូលអ្វីផ្សេង ក្រៅពីមូលនិធិឃុំ/សង្កាត់ដែលទទួលបានមួយដងក្នុងមួយឆ្នាំនោះទេ។ ជំនួយទ្រទ្រង់ (ផ្នែកហិរញ្ញវត្ថុ) បន្ថែមតែមួយគត់សម្រាប់ជួយពួកយើងឲ្យធ្វើការបម្រើប្រជាជន គឺការជួយទ្រទ្រង់មួយចំនួនទទួលបានពីអង្គការមិនមែនរដ្ឋាភិបាល។ *មេឃុំ នៅខេត្តបាត់ដំបង ថ្ងៃទី១២ កក្កដា ២០១០*

ឧបសគ្គមួយទៀតក្នុងការទាក់ទាញស្ត្រីដែលមានសមត្ថភាព អាចបញ្ចេញនូវទស្សនៈនយោបាយរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាឃុំ និងចំណង់ចំណូលចិត្តនិងតម្រូវការរបស់ប្រជាជនក្នុងមណ្ឌលបោះឆ្នោត គឺកង្វះស្ត្រីដែលមានគុណសម្បត្តិ ភាពក្លាហាន និងការយកចិត្តទុកដាក់ចង់ចូលរួមក្នុងអាជ្ញាធរមូលដ្ឋាន ពីព្រោះស្ត្រី (និងបុរស) ភាគច្រើននៅជនបទ តែងរារែកក្នុងការធ្វើសេចក្តីសម្រេចដែលមានការប្រទាំងប្រទើសច្រើន។[៨] សមាជិកក្រុមប្រឹក្សាឃុំមួយក្រុមនៅខេត្តកំពង់ចាម បានចែករំលែកទស្សនៈគាត់ថា៖

បញ្ហាយេនឌ័រពិតជាល្អមែននៅលើក្រដាស។ ពួកយើងបានមើលឃើញថា មានទីភ្នាក់ងារជាច្រើនកំពុងធ្វើការលើកកម្ពស់ការយល់ដឹងពីយេនឌ័រ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង វាមិនទាន់មានលក្ខណៈប្រាកដនិយមទេ។ បញ្ហាចម្បងៗនៃ (សមភាព) យេនឌ័រ គឺគុណសម្បត្តិ និងទំនុកចិត្តលើខ្លួនឯងនៃបេក្ខនារី។ ស្ត្រីដែលមានគុណសម្បត្តិគ្រប់គ្រាន់ មិនមានច្រើនទេក្នុងគណបក្សនយោបាយ ហើយនារីក្មេងៗដែលមានគុណសម្បត្តិគ្រប់គ្រាន់ មិនចូលចិត្តធ្វើការជាមួយអាជ្ញាធរមូលដ្ឋានឡើយ។ *សមាជិកក្រុមប្រឹក្សាឃុំមួយក្រុម នៅខេត្តកំពង់ចាម ថ្ងៃទី២៨ កក្កដា ២០១០*

អ្នកផ្តល់ព័ត៌មានជាច្រើនអះអាងថាអ្នកដឹកនាំជាស្ត្រីនៅកម្រិតឃុំត្រូវការលក្ខខណ្ឌខុសពីបុរសដើម្បីអាចបញ្ចេញមតិរបស់ខ្លួនបានត្រឹមត្រូវ។ លក្ខខណ្ឌទាំងនោះ រួមមាន៖ ១ ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងសិទ្ធិអំណាចសម្រេចចិត្តដូចមានចែងក្នុងច្បាប់ ២ ការគាំទ្រពេញលេញ ការអនុញ្ញាត និងទំនុកចិត្តពីសំណាក់គណបក្សនយោបាយ ៣ កម្រិតអប់រំច្បាស់លាស់ (ខ្ពស់ជាងបុរស) ឬសមត្ថភាពផ្នែកប្រាជ្ញា បទពិសោធន៍ការងារ ការយល់ដឹងល្អពីសហគមន៍ និងទំនុកចិត្តលើខ្លួនឯង និង ៤ ចរិយាសម្បត្តិល្អ និងប្រជាប្រិយភាពនៅក្នុងសហគមន៍។ បន្ទាប់មក មានសំនួរផុសឡើងថា តើអ្នកតំណាងត្រូវកសាងឥទ្ធិពលរបស់ខ្លួនតាមរបៀបណា និងប្រើប្រាស់ឥទ្ធិពលនោះយ៉ាងដូចម្តេច។ ដូច្នេះគួរធ្វើការពិភាក្សាពីលទ្ធភាពរបស់ស្ត្រីក្នុងការប្រើអំណាចរបស់ខ្លួន ឆ្លងតាមកំណើនសមត្ថភាពក្នុងការបញ្ចេញមតិអំពីចំណង់ចំណូលចិត្តរបស់ខ្លួន។

### *.....ប៉ុន្តែ គេបានដឹងឮកម្រិតណាដែរអំពីការបញ្ចេញមតិរបស់ស្ត្រី?*

នៅកម្ពុជាអ្នកដឹកនាំ (បុរស ឬស្ត្រី) លំបាកនឹងរក្សាភាពឯករាជ្យ (Kim 2012)។ភាពជាមេកើយឆ្លងតាមបណ្តាញធំទូលាយតាមខ្សែយរ គេតែងគិតថាជារឿងធម្មតា ឬក៏ជាកាតព្វកិច្ចតែម្តង (Chandler 2000; Marson 1997; Pak *et al.* 2007; Kim 2012) ហើយរចនាសម្ព័ន្ធអំណាចក្រៅផ្លូវការ តែងតែប្រកួតប្រជែងជានិច្ចជាមួយឋានានុក្រមក្នុងស្ថាប័នរដ្ឋ (Roberts 2006; Ledgerwood & Vijghen 2002)។ លំនាំជាទូទៅតាំងពីដើមរៀងមក គឺអំណាចវាផ្សារភ្ជាប់នឹងបុគ្គល

---

[៨] បញ្ហានេះបណ្តាលមួយផ្នែកមកពីការក្រាញជំទាស់ដែលធ្លាប់មានពីមុន ចំពោះការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តផ្នែកនយោបាយ (ដែលបង្កើតជាអន្ទាក់វិលវង់នៃការផាត់ចេញ) និងមួយផ្នែកមកពីការរារែកជាទូទៅក្នុងការលើកមតិដែលខ្លួនអាចមិនមានលទ្ធភាពបង្ហាញភស្តុតាង និងដែលជាចរិតលក្ខណៈទូទៅមួយរបស់ប្រជាជននៅជនបទ ព្រោះប្រសិនបើមាន "កំហុស" អ្វីមួយ អាចមានការចំអកធ្ងន់ធ្ងរយូរឆ្នាំអំពីមហាជន។ បញ្ហានេះកើតមានទាំងលើបុរស និងស្ត្រី ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងមានការដាក់ទោសធ្ងន់ជាងទៅលើអ្នកមានចរិតអំណួត និងអ្នកបំពានលើបែបបទមានស្រាប់។ ដូច្នេះ ស្ត្រីដែលហ៊ានប្រថុយចូលក្នុងកិច្ចការនយោបាយ អាចងាយរងគ្រោះខ្លាំងដោយសារ "ការគំរាមគំហែង" ប្រភេទនេះ។

និងស្ថិតក្នុងកណ្តាប់ដៃរបស់បុគ្គល ឬក្រុមផ្សេងៗ ហើយកម្រនៅជាមួយស្ថាប័នរដ្ឋផ្លូវការណាស់ (Mabbett & Chandler 1995; Thion 1993)។ នៅកម្រិតមូលដ្ឋាន មានការពឹងផ្អែកច្រើនណាស់ជាលក្ខណៈបុគ្គល និងក្នុងករណីមួយចំនួនមានខ្សែរយៈទាក់ទងជាមួយគណបក្សនយោបាយ (Pak & Craig 2008)។ នៅកម្ពុជាសម័យនេះ អំណាចប្រមូលផ្តុំនៅលើផ្នែកសំខាន់ៗបី៖ ផ្នែកឯកជន (បុគ្គល ឬអំណាចផ្សារភ្ជាប់នឹងបុគ្គល) ផ្នែកសាធារណៈ (ស្ថានប័នរដ្ឋ/រដ្ឋាភិបាល) និងគណបក្សនយោបាយ។ ដូច្នេះ គេត្រូវស្វែងរកឥទ្ធិពលតាមរយៈផ្នែកដ៏សំខាន់ទាំងនេះ ដែលស្ត្រីអាចមិនសូវមានលទ្ធភាពទៅជួបទាក់ទង។

អ្នកផ្តល់ព័ត៌មាន បានឆ្លើយសម្ភាសន៍ បង្ហាញនូវទស្សនៈខុសៗគ្នាពីរបៀបប្រើប្រាស់អំណាចដោយពេញច្បាប់នៅតាមមូលដ្ឋាន។ សមាជិកក្រុមប្រឹក្សាឃុំមួយក្រុម នៅខេត្តកំពង់ចាម បានលើកពីចំណាប់អារម្មណ៍របស់ខ្លួនថា៖

> ក្នុងស្ថានភាពបច្ចុប្បន្នក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាឃុំ ពួកយើងមិនអាចឯករាជ្យបានទេ។ ពួកយើងត្រូវប្តូរផ្តាច់ចំពោះគណបក្សនយោបាយ ព្រោះប្រព័ន្ធនេះធ្វើការតាមរយៈបញ្ជីគណបក្ស។ ចំណង់ចំណូលចិត្តរបស់គណបក្សនយោបាយ មានអានុភាពខ្លាំងបំផុត ហើយយើងមិនអាចផ្លាស់ប្តូរបានទេ។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តកំពង់ចាម ថ្ងៃទី២៨ កក្កដា ២០១០*

មេឃុំស្ត្រីម្នាក់ នៅខេត្តបាត់ដំបង បានបង្ហាញទស្សនៈលើកត្តានយោបាយដ៏សំខាន់ៗបំផុតថា៖

> នាបច្ចុប្បន្នប្រព័ន្ធបោះឆ្នោតរបស់យើងឈរលើការបោះឆ្នោតឲ្យគណបក្សគិតតាមសមាមាត្រ។ (ខ្សែរយៈទាក់ទងជាមួយ) គណបក្សនយោបាយ ជាកត្តាសំខាន់បំផុតសម្រាប់ការប្រើប្រាស់អំណាច។ កត្តាសំខាន់ទី២ គឺសមត្ថភាពបុគ្គល និងការប្តេជ្ញាចិត្ត ហើយកត្តាទី៣ គឺរដ្ឋ ឬឃុំ។ យើងត្រូវការកត្តាទាំងបីនេះ ដើម្បីទទួលបានការគាំទ្រពីប្រជាជនក្នុងសហគមន៍ និងធ្វើការងារបានជោគជ័យ។ លោកអ្នកអាចប្រៀបធៀបទៅនឹងជើងក្រានដែលត្រូវមានជុំទម្រនៅបីជ្រុង ទើបអាចដាក់ឆ្នាំងបាយនឹងល្អ។ *មេឃុំស្ត្រីមួយរូប នៅខេត្តបាត់ដំបង ថ្ងៃទី១២ កក្កដា ២០១០*

ដើម្បីមានអំណាចពេញច្បាប់ អ្នកដឹកនាំគួរដឹងច្បាស់ពីធាតុស្នូលទាំងបីនៃអំណាច។ មេឃុំស្ត្រីមួយរូប នៅខេត្តក្រចេះ បានលើកថា៖

> ខ្ញុំសូមចែករំលែកជាមួយលោកអ្នកថា នាបច្ចុប្បន្ន អំណាចនៅកម្រិតឃុំ វាជាប់ពាក់ព័ន្ធជាមួយបុគ្គលិកលក្ខណៈរបស់បុគ្គល រដ្ឋអំណាច និងគណបក្សនយោបាយ។ រដ្ឋ ឬឃុំ ជាធាតុសំខាន់ជាងគេក្នុងចំណោមធាតុទាំងបី ព្រោះត្រូវទទួលខុសត្រូវលើការអនុវត្តក្របខ័ណ្ឌច្បាប់របស់រដ្ឋាភិបាល។ ធាតុសំខាន់ទី២ គឺសមត្ថភាពអ្នកដឹកនាំ និងប្រជាប្រិយភាពរបស់ពួកគេ ហើយធាតុទី៣ គឺ គណបក្សនយោបាយ ព្រោះពួកយើងនៅក្នុងប្រព័ន្ធបោះឆ្នោតផ្អែកលើបញ្ជីគណបក្ស។ *មេឃុំស្ត្រី នៅខេត្តក្រចេះ ថ្ងៃទី១៩ មិថុនា ២០១០*

ការបែងចែករវាងរដ្ឋ និងគណបក្សនយោបាយនៅតែមិនទាន់ច្បាស់លាស់។ អ្នកនយោបាយនៅតាមមូលដ្ឋានជាច្រើន នៅតែកំពុងបន្តអនុវត្តនូវប្រព័ន្ធសាធារណរដ្ឋប្រជាមានិតកម្ពុជា (PRK) តាំងពីទសវត្ស៍១៩៨០ នោះទៀត ដែលមានន័យថា បក្សដឹកនាំ ហើយរដ្ឋអនុវត្ត ឬបក្សជាទី១ ហើយ រដ្ឋជាទី២។ ទោះបីកំពុងអនុវត្តក្តី ក៏របៀបរបបនេះហាក់ចាស់ហួសសម័យទៅហើយ នៅក្នុងប្រព័ន្ធអភិបាលកិច្ចដែលកំពុងផុសឡើង។ ប៉ុន្តែការជជែកអះអាងពីភាពហួសសម័យ មិនបានរារាំងដល់ប្រសិទ្ធភាពនៃប្រព័ន្ធនេះទេ ទោះបីវាមានលក្ខណៈបុរាណបន្តិចក្តី។ សមាជិកក្រុមប្រឹក្សាឃុំមួយរូប នៅខេត្តតាកែវ បានបកស្រាយបន្ថែមថា៖

> តាមប្រព័ន្ធបោះឆ្នោតផ្អែកលើគណបក្សនាបច្ចុប្បន្ន (យុទ្ធសាស្ត្រ) សំខាន់បំផុតសម្រាប់បុគ្គលដើម្បីមានអំណាច ឬមុខងារក្នុងរដ្ឋាភិបាល គឺត្រូវមានមុខតំណែងល្អក្នុងគណបក្សនយោបាយ ព្រោះពួកយើង

នៅតែជឿថា បក្សដឹកនាំ ហើយរដ្ឋអនុវត្ត។ កត្តាផ្សេងទៀតសម្រាប់បង្កើតអំណាច គឺសមត្ថភាពបុគ្គល បណ្ដាញ និងប្រជាប្រិយភាពក្នុងគណបក្ស និងសហគមន៍។ ទាំងនេះជាកត្តានានា ដែលក្រុមប្រឹក្សាឃុំត្រូវប្រតិបត្តិតាម។ *សមាជិកក្រុមប្រឹក្សាឃុំ នៅខេត្តតាកែវ ថ្ងៃទី២៤ មិថុនា ២០១០*

សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តកំពង់ចាម បានបង្ហាញទស្សនៈពីរចនាសម្ព័ន្ធអំណាច និងការសម្រេចចិត្តរបស់គណបក្សនយោបាយ ថា៖

ច្បាប់រដ្ឋដ៏ត្រឹមត្រូវសមហេតុផលសំខាន់ខ្លាំងណាស់ សម្រាប់ការអនុវត្តប្រចាំថ្ងៃ នូវគោលនយោបាយរដ្ឋាភិបាល និងការចាត់ចែងដោះស្រាយជាមួយប្រជាជន ប៉ុន្តែគណបក្សមានអំណាចសម្រេចចិត្តបណ្ដេញចោល ឬរក្សាទុករូបអ្នកក្នុងមុខតំណែង ដូច្នេះគណនេយ្យភាពចំពោះបក្សវាសំខាន់ដូចគ្នា។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តកំពង់ចាម ថ្ងៃទី២៨ កក្កដា ២០១០*

សមាជិកជាន់ខ្ពស់នៃក្រុមប្រឹក្សាឃុំមួយរូបមកពីគណបក្សកាន់អំណាច នៅខេត្តក្រចេះ បានពិពណ៌នាពីអំណាចសម្រេចចិត្តរបស់បក្សគាត់ថា៖

ចំណុចស្នូលនៃអំណាចសម្រេចចិត្តនៅក្នុងបក្ស វាអាស្រ័យលើលទ្ធផលការងារសម្រាប់បក្ស ការប្ដូរផ្ដាច់ចំពោះបក្ស និងប្រជាប្រិយភាពក្នុងចំណោមប្រជាជន ដែលធ្វើឲ្យបក្សជឿទុកចិត្តលើរូបអ្នក។ សមត្ថភាព និងការអប់រំមិនមែនជាអាទិភាពទី១ ទេ ព្រោះក្នុងស្ថានភាពនយោបាយបច្ចុប្បន្ន បក្សត្រូវផ្ដល់អាទិភាពលើការទទួលបានសន្លឹកឆ្នោតច្រើន និងជោគជ័យក្នុងការបោះឆ្នោត។ តាមធម្មតា មនុស្សម្នាក់មិនអាចបំពេញតាមតម្រូវការទាំងអស់នេះទេ ប៉ុន្តែសមត្ថភាព និងការអប់រំ អាចដោះស្រាយកែលំអតាមក្រោយបាន តាមរយៈបទពិសោធន៍ការងារ។ *សមាជិកក្រុមប្រឹក្សាឃុំបុរសម្នាក់ នៅខេត្តក្រចេះ ថ្ងៃទី២៥ មេសា ២០១២*

ការខុសប្លែកគ្នាខ្លះៗពីសេចក្ដីខាងលើ អាចមានជាកំណើនសារៈសំខាន់នៃប្រាក់កាសនៅក្នុងកិច្ចការនយោបាយតាមមូលដ្ឋាន។ មេឃុំស្ត្រីម្នាក់ បានបង្ហាញទស្សនៈពី ទំនាក់ទំនាក់រវាងគណបក្សនយោបាយនឹងរដ្ឋ ថាចំពោះប្រព័ន្ធបោះឆ្នោតបច្ចុប្បន្ន បើគ្មានគណបក្ស ក៏គ្មានរដ្ឋដែរ ហើយអ្នកណាក៏ដោយឲ្យតែមានប្រាក់ គឺអាចឡើងកាំថ្នាក់អំណាចក្នុងគណបក្សនយោបាយ។ គាត់និយាយថា៖

រចនាសម្ព័ន្ធអំណាចបច្ចុប្បន្ន មានលក្ខណៈសាមញ្ញ (ហើយនៅដដែល) ដូចកាលពីឆ្នាំ១៩៧៩ ដែរ។ គណបក្សនយោបាយសំខាន់បំផុត ព្រោះបើ "គ្មានបក្ស គ្មានរដ្ឋ" ទេ។ នេះជាពាក្យស្លោកនយោបាយតាំងពីទសវត្សរ៍១៩៨០ហើយវានៅដដែលរហូតមកដល់សព្វថ្ងៃ។ខ្ញុំគិតថា សមត្ថភាព និងប្រជាប្រិយភាពរបស់បុគ្គល ក៏សំខាន់ណាស់ដែរ ព្រោះអាចធ្វើឲ្យគណបក្សឈ្នះឆ្នោត ហើយប្រជាជនក្នុងសហគមន៍ក៏គាំទ្ររូបអ្នក... ប្រាក់កាសឥឡូវនេះសំខាន់បំផុត។ ប្រាក់បង្កើតអំណាច និងប្រាក់។ បើអ្នកជាអ្នកមាន អ្នកក៏មានអំណាចក្នុងបក្សដែរ ហើយអាចជាប់ឈ្មោះនៅលើគេក្នុងបញ្ជីបេក្ខជនរបស់បក្ស នៅពេលបោះឆ្នោត រួចបន្ទាប់មកទទួលបានមុខតំណែងប្រកបដោយកិត្តិយស។ *មេឃុំ នៅខេត្តតាកែវ ថ្ងៃទី២៥ មិថុនា ២០១០*

ក្រុមមួយផ្សេងទៀតនៅខេត្តតាកែវ បានពិពណ៌នាពីទស្សនៈរបស់ខ្លួនស្ដីពីអំណាចនៅកម្ពុជា៖

គណបក្សនយោបាយ សមត្ថភាពបុគ្គល និងអាជ្ញាធរ(រដ្ឋ) សំខាន់ខ្លាំងដូចគ្នា ប៉ុន្តែសព្វថ្ងៃ អំណាចពិតប្រាកដពឹងផ្អែកជាបឋមលើប្រាក់កាស រួចបន្ទាប់មកលើគណបក្សនយោបាយ និងអាជ្ញាធរ។ បេក្ខជនអ្នកមានប្រាក់ដែលប្រជែងយកតំណែងនយោបាយ គឺមានប្រជាប្រិយភាពក្នុងចំណោមប្រជាជន ហើយ

បក្សក៏ជឿទុកចិត្តដែរ ព្រោះពួកគេអាចទទួលបានលទ្ធផលបោះឆ្នោតល្អសម្រាប់បក្ស។ *សមាជិកក្រុមប្រឹក្សាឃុំបុរសមួយក្រុម នៅខេត្តតាកែវ ថ្ងៃទី២៤ មិថុនា ២០១០*

រូបភាព ៣ បង្ហាញនូវព័ត៌មានជាក់ស្តែងបានពីការចុះធ្វើសម្ភាសន៍ជាមួយក្រុមប្រឹក្សាឃុំ និងអ្នកដឹកនាំអាជ្ញាធរភូមិ។ រចនាសម្ព័ន្ធបីដែលមានឥទ្ធិពលខ្លាំងក្នុងសង្គមកម្ពុជា វាឆ្លុះបញ្ចាំងពី បែបបទនៃការប្រមូលយក និងរក្សាទុកអំណាចជានិរន្តរ៍។ ដើម្បីការពារអំណាចរបស់ខ្លួន ដែននយោបាយដ៏សំខាន់បំផុត (តាមទស្សនៈយេនឌ័រ) គឺស្ត្រីត្រូវចូលរួមយ៉ាងសកម្មក្នុង និងទទួលបានទំនុកចិត្តពីគណបក្សនយោបាយ (ដោយសារការប្រើប្រព័ន្ធបញ្ជីឈ្មោះពីគណបក្ស)។ដែនសំខាន់បំផុតទី២គឺផ្នែកបុគ្គល/ឯកជនដែលតម្រូវឲ្យស្ត្រីចេះដាក់ខ្លួនមានប្រជាប្រិយភាពនិងចិត្តអំណត់នៅក្នុងសហគមន៍។ ដែននយោបាយសំខាន់ទី៣ គឺ ស្ថាប័នរដ្ឋ ដូចជា ឃុំជាដើម ដែលមានហេតុផលត្រឹមត្រូវ និងអំណាចស្របច្បាប់ដើម្បីគ្រប់គ្រងត្រួតត្រា។ ក្នុងចំណោមដែនសំខាន់ទាំងបី ស្ត្រីទំនងជាទទួលបានជោគជ័យខ្លាំងជាងគេក្នុងការបង្កើតការគាំទ្រពីមហាជន ដោយប្រើប្រាស់សមត្ថភាពឯកជន និងដោយទទួលបានការជួយទ្រទ្រង់មួយផ្នែកពីគោលនយោបាយ និងច្បាប់រដ្ឋ។ ការគាំទ្របានពីក្នុងបក្សមានកម្រិតតិចតួចជាង ដោយទទួលរងការគាបសង្កត់ពីការគ្រប់គ្រងបែបបុរាណ និងការផុសចេញនូវនយោបាយប្រើប្រាក់កាស ដែលសុទ្ធតែអំណោយផលទៅខាងបុរស។

រូបភាព ៣៖ រចនាសម្ព័ន្ធអំណាចនៅថ្នាក់ឃុំ/សង្កាត់




សរុបមក ដំណើរការនយោបាយសំខាន់ៗបំផុតដែលអាចជួយជំរុញអំណាចស្ត្រីនោះ យើងបានរកឃើញដូចតទៅ៖

- សមត្ថភាពរបស់ស្ត្រីក្នុងការបញ្ចេញទស្សនៈនយោបាយ នៅក្នុងអង្គភាពផ្លូវការ បានកើនឡើងតាមរយៈដំណើរការវិមជ្ឈការ។គេយល់ឃើញថាស្ត្រីពូកែនិងយកចិត្តទុកដាក់ក្នុងការបញ្ចេញទស្សនៈខាងនយោបាយ ជាពិសេសទាក់ទងនឹងបញ្ហាសុខុមាលភាពរបស់កុមារ ស្ត្រី និងសង្គម។
- អ្នកដឹកនាំជាស្ត្រី ត្រូវប្រឈមមុខនឹងឧបសគ្គបន្ថែម[៩] ដូចជា ការពឹងផ្អែក (ជាងគេ) លើធនធានហិរញ្ញវត្ថុពីរដ្ឋាភិបាលកណ្តាល គណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល។ ជារឿយៗ កិច្ចសហប្រតិបត្តិការពីសំណាក់បុរស និងគណបក្សនយោបាយ ជាការចាំបាច់ ដើម្បីឲ្យស្ត្រីអាចបញ្ចេញមតិ និងអនុវត្តអាទិភាពនានារបស់ខ្លួនបានល្អ។

[៩] វាក៏ជាឧបសគ្គចំពោះសមាជិកក្រុមប្រឹក្សាជាបុរសដែរ ប៉ុន្តែតាមសេចក្តីរាយការណ៍ វារឹតតែលំបាកថែមទៀតចំពោះស្ត្រី។

- កិច្ចពិភាក្សាជាច្រើនពីបញ្ហាយេនឌ័រនៅកម្ពុជា បានផ្តោតលើការសន្មតពីកង្វះភាពជឿជាក់លើខ្លួនឯងក្នុងចំណោមស្ត្រី ដែលធ្វើឲ្យពួកគេជួបការលំបាក។ ដូចមានបង្ហាញក្នុងការពិភាក្សាជាក់ស្តែងខាងលើ ដើម្បីមានអំណាចបន្ថែមទៀត ស្ត្រីត្រូវការនូវស្វ័យភាព ទំនុកចិត្ត និងការគាំទ្រ ក្នុងកម្រិតណាមួយពីគណបក្សនយោបាយ និងក្រុមគ្រួសារ។
- ការផ្តល់អំណាចដល់ស្ត្រីក្នុងកិច្ចការនយោបាយ វាអាស្រ័យជាខ្លាំងលើការផ្តល់អាទិភាពឲ្យស្ត្រីនៅក្នុងគណបក្សនយោបាយ ដោយដាក់ឈ្មោះពួកគេនៅលើបំផុតក្នុងបញ្ជីបោះឆ្នោត និងផ្តល់សិទ្ធិអំណាច និងការគាំទ្រដល់ពួកគេ។
- ជារួម ស្ត្រីកាន់តែមានច្រើន និងទទួលបានការពេញចិត្តនៅក្នុងក្រុមប្រឹក្សាឃុំ ហើយការជជែកវែកញែកក្នុងចំណោមមហាជន ក៏បានជួយលើកទឹកចិត្តមួយកម្រិតឲ្យស្ត្រីចូលរួមក្នុងកិច្ចការនយោបាយនៅមូលដ្ឋានដែរ ពោលគឺ ឲ្យស្ត្រីមានភាពសកម្ម និងបញ្ចេញទស្សនៈរបស់ខ្លួន។ ទោះយ៉ាងនេះក្តី លទ្ធភាពតូចរបស់ស្ត្រីក្នុងការជួបពាក់ព័ន្ធជាមួយ "មូលដ្ឋានគ្រឹះនៃអំណាច" ក្នុងសង្គម បានរារាំងស្ត្រីក្នុងការប្រើប្រាស់អំណាចបានស្មើភាពគ្នាជាមួយបុរស។

# ៤
# ការពិភាក្សា និង សេចក្តីសន្និដ្ឋាន

ការសិក្សានេះ មានបំណងពិនិត្យថា តើការបែងចែកសិទ្ធិអំណាចបែបប្រជាធិបតេយ្យ បានបើកចំហឲ្យស្ត្រីចូលរួមក្នុងកិច្ចការនយោបាយមូលដ្ឋានត្រឹមកម្រិតណា។ ក្នុងការពិនិត្យពីកិច្ចការនយោបាយមូលដ្ឋាន ដោយធ្វើការវិភាគលើវិធីសាស្ត្ររាប់ចំនួនមនុស្ស យើងបានអនុវត្តវិធីសាស្ត្រស្មើភាពគ្នាមួយ ដើម្បីសិក្សាស្រាវជ្រាវជាក់ស្តែង ទៅលើការចូលរួមរបស់ស្ត្រីក្នុងអភិបាលកិច្ចនៅមូលដ្ឋានក្នុងពីរកម្រិតផ្សេងគ្នា៖ ទី១ គឺ *ទំហំនៃភាពជាតំណាងផ្នែកនយោបាយរបស់ស្ត្រីក្នុងក្រុមប្រឹក្សាឃុំ* តាមរយៈសំណួរដូចជា តើភាពជាតំណាងផ្នែកនយោបាយរបស់ស្ត្រីបានរីកចម្រើនយ៉ាងដូចម្តេច, ហេតុអ្វី និងជះឥទ្ធិពលយ៉ាងដូចម្តេច។ កម្រិតទី២ គឺ *ការបញ្ចេញមតិ និងការអនុវត្តសិទ្ធិអំណាចក្នុងតួនាទីជាអ្នកនយោបាយនៅមូលដ្ឋាន*។ តើការលើកពីមតិ និងចំណង់ចំណូលចិត្តរបស់ស្ត្រី មានអនុវត្តយ៉ាងដូចម្តេចនៅក្នុងក្រុមប្រឹក្សាឃុំ? តើយន្តការណាខ្លះជួយឲ្យស្ត្រីអាចប្រឹងតស៊ូដើម្បីទទួលបានអំណាចក្នុងក្រុមប្រឹក្សាឃុំ និង តើមានឧសគ្គអ្វីខ្លះ? ការពិភាក្សាក្នុងជំពូកនេះ នឹងបកស្រាយលំអិតលើសំណួរទាំងនេះ។

## ៤.១. វិមជ្ឈការ និងភាពជាតំណាងផ្នែកនយោបាយមានលក្ខណៈយេនឌ័រនៅក្នុងក្រុមប្រឹក្សាឃុំ

ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិសម្រាប់ការផ្តល់អំណាចផ្នែកនយោបាយឲ្យស្ត្រី និងចំនួនស្ត្រីចូលរួមក្នុងវេទិកានយោបាយ នៅតាមផ្នែកផ្សេងៗនៃរដ្ឋាភិបាល បង្ហាញយ៉ាងច្បាស់ថា រដ្ឋាភិបាលបានពិចារណាយ៉ាងយកចិត្តទុកដាក់លើតួនាទីរបស់ស្ត្រីក្នុងវិស័យនយោបាយ។ ភាពជឿជាក់ថាបញ្ហានេះសំខាន់ កំពុងផុសឡើងតាមរយៈកំណែទម្រង់គោលនយោបាយ និងក្របខ័ណ្ឌច្បាប់នានា។ ដូច្នេះ ការបញ្ជ្រាបយេនឌ័រ កំពុងធ្វើឡើងជាបន្តបន្ទាប់តាមរយៈយន្តការគោលនយោបាយផ្សេងៗ ហើយសំខាន់បំផុតតាមរយៈការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ នៅកម្រិតអាជ្ញាធរមូលដ្ឋាន ការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ មិនមែនជារឿងថ្មីទេ ប៉ុន្តែ "បែបបទថ្មី" មួយកំពុងតែផុសឡើងដែលក្នុងនោះមានស្ត្រីចូលរួមជាតំណាងកាន់តែញឹកញាប់ជាងមុន ក្នុងវេទិកាផ្លូវការនានា ហើយជួនកាលមានការទទួលស្គាល់ជាអ្នកដឹកនាំពេញច្បាប់ និងមានសមត្ថភាពទៀតផង។ នេះជាភស្តុតាងច្បាស់ថា កំណែទម្រង់វិមជ្ឈការ ជាពិសេសការបង្កើតការបោះឆ្នោតឃុំ/ក្រុមប្រឹក្សាឃុំ បានបើកចន្លោះសម្រាប់ឲ្យស្ត្រីបានចូលរួមក្នុងកិច្ចការនយោបាយនៅមូលដ្ឋានដល់កម្រិតមួយដែលមិនធ្លាប់មានពីមុនមក។

ការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គមកិច្ចជាបន្តបន្ទាប់នៅកម្ពុជា បានជះឥទ្ធិពល និងផ្លាស់ប្តូរតួនាទីរបស់ស្ត្រីជាច្រើនបែបយ៉ាង។ បែបបទជាប្រពៃណី និងគំនិតសន្មតចាស់គម្រិលចំពោះស្ត្រី បានថយឥទ្ធិពលជាបណ្តើរៗដោយសារមូលហេតុជាច្រើន រួមមាន៖ កត្តាជំរុញឲ្យស្ត្រីត្រូវតែ ឬចង់ធ្វើការឆ្ងាយពីផ្ទះ គួបផ្សំនឹង ការជំទាស់និងហានិភ័យតិចជាងមុន និងឱកាសច្រើនជាងមុនសម្រាប់ឲ្យពួកគេធ្វើដូច្នោះ។ កត្តាអូសទាញមានដូចជា តម្រូវការថ្នាក់ដឹកនាំមូលដ្ឋានកាន់តែមានលក្ខណៈពេញច្បាប់ និងល្អប្រសើរដែលស្ត្រីអាចជួយបំពេញឲ្យបាន។ ប្រព័ន្ធផ្សព្វផ្សាយ ការតស៊ូមតិដើម្បីការអភិវឌ្ឍ និងការកសាងសមត្ថភាពជាទូទៅផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាលនិងផ្តោតលើស្ត្រី ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនការយល់ដឹងអំពីបញ្ហាយេនឌ័រ និងទប់ទល់នឹងការវែកញែកថា មិនមានស្ត្រីមានជំនាញសក្តិសមនឹងតួនាទីថ្នាក់ដឹកនាំផ្នែកនយោបាយទេ។

ដោយមានបញ្ហាដូចខាងលើ ការធ្វើឲ្យស្មើភាពគ្នាក្នុងភាពជាតំណាងផ្នែកនយោបាយ ពិតជាត្រូវប្រឈមមុខនឹងបញ្ហារាំងដែលបានចាក់ឫសយ៉ាងជ្រៅ។ ការរាប់ចំនួនជាក់ស្តែង បង្ហាញពីភាពរីកចម្រើននៃដំណើរការពង្រឹងយេនឌ័រក្នុងកិច្ចការនយោបាយ ប៉ុន្តែអ្នកនយោបាយបុរស នៅតែគ្របដណ្តប់លើគ្រប់កម្រិតក្នុងជួររដ្ឋាភិបាល ហើយតែងមានជានិច្ចនូវ "ការជជែកវែកញែកក្រាស់ឃ្មឹក" សម្រាប់សំអាងនៅពេលមានតម្រូវការ ដែលកំហិតនូវលទ្ធភាពសម្រាប់ឲ្យស្ត្រីធ្វើជាអ្នកដឹកនាំមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។ ស្ត្រីនានាបានដឹងពីគំនិតនេះ (ថៃមពីលើលក្ខខណ្ឌ

ពីបុរាណនោះទៀត) ហើយអន្ទាក់វិលវង់មួយក៏ផុសឡើង គឺពិបាករកបានបេក្ខនារីមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីបម្រើការប្រកបដោយប្រសិទ្ធភាពក្នុងវេទិកានយោបាយនៅមូលដ្ឋាន ដូចគេបានពិនិត្យឃើញនៅកន្លែងឯទៀតដែរ ហើយស្ត្រីក៏មានស្ថានភាពងាយរងគ្រោះជាងបុរស នឹងការទិទៀលពីសាធារណជន។ ម្យ៉ាងទៀត ច្បាប់ និងគោលនយោបាយនានាច្រើនតែល្អប្រសើរនៅលើក្រដាស ជាជាងនៅពេលយកទៅអនុវត្តជាក់ស្តែង។ សំខាន់បំផុត បើពិនិត្យដល់ចំណុចស្នូលនៃរចនាសម្ព័ន្ធអំណាចនយោបាយទៅ គេឃើញថា គណបក្សនយោបាយមិនទាន់សកម្មប្រយុទ្ធក្នុងការពង្រឹងសមភាពយេនឌ័រនោះទេ។ ដូច្នេះ ពុំមានឆន្ទៈនយោបាយអ្វីពិតប្រាកដ ដើម្បីលើកទឹកចិត្តស្ត្រីឲ្យចូលរួមក្នុងកិច្ចការនយោបាយមូលដ្ឋានឡើយ។ យ៉ាងណាក្តី ពួកយើងអាចអះអាងថា មានការធ្លាក់ចុះគួរឲ្យកត់សម្គាល់នូវការប្រឆាំងនឹងការទទួលស្គាល់ស្ត្រីក្នុងកិច្ចការនយោបាយ និងមានការចាប់អារម្មណ៍លើយុទ្ធសាស្ត្រថ្មីមួយ ក្នុងការដាក់បេក្ខនារីនៅលើគេក្នុងបញ្ជីគណបក្ស ព្រោះឥឡូវនេះវាអាចទាញទាញសម្លេងឆ្នោតពីមហាជន។

## ៤.២. លទ្ធភាពស្ត្រីក្នុងការបញ្ចេញមតិអំពីអាទិភាពផ្នែកនយោបាយ និងទស្សនៈផ្សេងៗ

ទោះបីភាពជាតំណាងរបស់ស្ត្រីក្នុងកិច្ចការនយោបាយមូលនៅដ្ឋាន បានកើនឡើងយ៉ាងច្បាស់ក្តី ក៏លទ្ធភាពស្ត្រីក្នុងការបញ្ចេញមតិ និងបញ្ជាក់ពីចំណង់ចំណូលចិត្ត និងតម្រូវការនៃមណ្ឌលបោះឆ្នោតរបស់ខ្លួន មិនប្រាកដថាបានកើនឡើងដូចគ្នានោះទេ។ ស្ត្រីតែងត្រូវបានគេចាត់ថាជាអ្នកទទួលបន្ទុកដោះស្រាយបញ្ហាស្ត្រី ដូចជា សុខុមាលភាពសង្គម អំពើហិង្សាក្នុងគ្រួសារ សេដ្ឋកិច្ចគ្រួសារ និងកិច្ចការកុមារ។ ចំណុចនេះគេយល់ថាជាវិធីសម្រាប់ពង្រឹងផ្នត់គំនិតយេនឌ័រ ប៉ុន្តែវាក៏ជាមធ្យោបាយមួយសម្រាប់ទម្លាយការជជែកវែកញែកឲ្យតម្លៃទាបជាងទៅលើស្ត្រី ភាពទន់ខ្សោយរបស់ស្ត្រី កង្វះប្រសិទ្ធភាពក្នុងការដោះស្រាយជាមួយប៉ូលីស និងកង្វះជំនាញជាអ្នកដឹកនាំ។ ក្នុងសម័យក្រោយសង្គ្រាម បញ្ហាទាំងនេះមិនមែនសុទ្ធតែបន្ទាប់បន្សំទេ ព្រោះជួនកាលអាចលេចធ្លោឡើងនៅក្នុងការជជែកវែកញែកពីការអភិវឌ្ឍនៅមូលដ្ឋាន។ ដូចយើងបានឃើញស្រាប់ ថ្នាក់ដឹកនាំជាស្ត្រីមួយចំនួន គាត់ទទួលបាននូវភាពពេញច្បាប់ផ្នែកនយោបាយនៅក្នុងមូលដ្ឋាន ដោយសារគាត់មានសមត្ថភាពល្អក្នុងវិស័យទាំងនោះ។

